សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
Advertising: PA/NJ/NY: (267) 253-3947 MA/RI: (978) 656-8141

មាតិការឿង Vol 07 Issue 128- April 26th- May 09th. 2013 ទំព័រ

១-សេចក្តីអំពាវនាវចំពោះ&រឿងបែកបាក់សាមគ្គីនៅវត្ត..........០៣
២-ខ្មែរអ្នកជាតិនិយម..........០៤
៣-អ្នកក្រនិងអ្នកមាននៅស្រុកខ្មែរ..........០៥
៤-The Cambodia daily..........០៦
៥- ក្តុបុលវិតណេសរាយការណ៍ពីស្ថានភាពនៅកម្ពុជា..........០៧
៦-បែកបាក់គ្នាគ្រប់គ្រាន់ហើយ..........១២

32 Wamesit St., Lowell, MA 01852. Phone-Fax (978) 656 8141 www.khmerpost.us

# Season of Cambodia

# ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃសិល្បៈវប្បធម៌ខ្មែរ ក្នុងទីក្រុងញូយ៉កសហរដ្ឋអាមេរិក



Phloeun Prim



●●●ទីក្រុងញូយ៉ក"វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន"។ ទឹកប្រាក់ជាង២លានកន្លះ ត្រូវបានយកមកចំណាយក្នុងការឧបត្ថម្ភគាំទ្រសិល្បករខ្មែរ១២៥នាក់ ដែលបានធ្វើដំណើរឆ្លងទ្វីបពីព្រះរាជាណាចក្រកម្ពុជាមកកាន់សហរដ្ឋអាមេរិក។ សិល្បៈតូរខ្មែរទាំង១២៥រូប បង្ហាញនូវទស្សនីយភាពសិល្បៈដ៏សំម្បូរបែបដែលខ្មែរបានអភិរក្ស និងអភិវឌ្ឍរួមមានការប្រគំ តទៅទំព័រទី ១៤

## ចូលឆ្នាំខ្មែរនៅ"វត្តសហគមន៍ព្រះសង្ឃខ្មែរ"

●●●ចូលឆ្នាំខ្មែរដូច"ខ្មែរនៅកណ្តាលស្រោច" ជារូបភាពនៃពិធីចូលឆ្នាំរោងនៅ"អាល់ក្លឹប" រៀបចំឡើងដោយវត្តសហគមន៍ព្រះសង្ឃខ្មែរនៅឡូវែលថ្ងៃទី១៣មេសា ព.ស២៥៥៧ ។ បាតុករប្រមាណជាង១០០នាក់ តទៅទំព័រទី ១១



## ដកស្រង់សេចក្តីថ្លែងការណ៍ជុំវិញការចោទប្រកាន់ និងការផ្សព្វផ្សាយពាក្យចចាមអារ៉ាម




ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៣

●●●អាត្មាភាពជាព្រះសង្ឃគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នាជាសមាជិកវត្តខ្មែរ ឡូវែល និងសហគមន៍ព្រះសង្ឃខ្មែរប្រចាំសហរដ្ឋអាមេរិក សូមចូលរួមមរណៈទុក្ខជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់នៃជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងការផ្ទុះគ្រាប់បែក តទៅទំព័រទី ១៤

## សម្ភាសន៍ជាមួយលោក សម រង្ស៊ី ស្តីពីស្ថានភាព គណបក្សសង្គ្រោះជាតិឡូវែល

●●●នាឱកាសមកធ្វើទស្សនៈកិច្ចនៅក្រុងឡូវែល កាលពីថ្ងៃទី១៣ ខែមេសា ២០១៣ កន្លងទៅនេះលោក សម រង្ស៊ី បានចូលរួមរីករាយក្នុងពិធីចូលឆ្នាំខ្មែររៀបចំដោយសហគមន៍ខ្មែរ និងក្រុងខ្មែរនៅព្រលានខ្មែរឱ្យឈ្មោះថា "ឧទ្យានប៉ៃលិន" ក្នុងតួនាទីថ្មីរបស់លោកជាប្រធានគណបក្សសង្គ្រោះជាតិ តទៅទំព័រទី ១០



ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
Immigration • Divorce • Auto Crash
▸ អន្តោប្រវេសន៍ ▸ គ្រោះថ្នាក់រថយន្ត ▸ លែងលះប្តីប្រពន្ធ
Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា ឬធំ
978-459-5000 or 800-308-3766
Only Licensed in Massachusets



ប្រើធនាគារឲ្យប្រសើរ
គឺនៅក្នុងកាបូប
FREE
$150 gift card to Coach*
កាតរង្វាន់$150ទិញកាបូបល្បីឈ្មោះ"ខូច"
ជាមួយការបើកសេវាសម្រាប់ប្រើធនាគាររាល់ថ្ងៃ
Washington SAVINGS BANK
washingtonsavings.com
* Restrictions apply Ask for details.
Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate" and implementing the following combination of new services after 12/10/2012: A monthly direct deposit of at least $1,000 from an unaffiliated third party, at least one monthly automatic withdrawal that is not web or card based and an active debit card with 12 or more completed purchases is eligible for a $150 Coach® gift certificate. Promotion ends 06/30/2013. Coach® is a trademark of Coach, Inc. The program is not endorsed by Coach, Inc. nor is there any actual or implied joint venture, partnership or relationship of any kind between Washington Savings Bank and Coach, Inc. Promotions cannot be combined, one gift per customer, per account, per household. Available to personal accounts only. Fee of $150 applies for account closure or change of services within 6 months of free gift receipt. Washington Savings Bank reserves the right to disqualify any account/ person from this promotion if, in its sole discretion, it determines the account and/or services are solely designed to qualify for the free gift. Limited time offer, while supplies last.

### ទស្សនៈមិត្តអ្នកអាន

# សូមបងប្អូនពិចារណា

**ដោយ : ពូខ**

ប៉ុន្តែឆ្នាំកន្លងទៅនេះ យើងឮដំណឹងចរចាមអារាមពីរឿងអាស្រូវដែលកើតឡើងនៅវត្តត្រៃរតនារាម "វត្តលើ" នៅទីក្រុង Lowell រដ្ឋ Massachusetts នូវប្រធានបទពីរ គឺអំពើកេងប្រវ័ញ្ចប្រាក់វត្ត និងសីលធម៌ខុសបែបបទ ។ ទាំងពីរនេះកំពុងស្ថិតក្នុងភាពសាំញ៉ាំជំពាក់ជំពិនមិនទាន់មានដំណោះស្រាយនៅឡើយ ។ ការមិនជ្រះស្រឡះនេះបណ្តាលឱ្យមានការប្រេះឆាក្នុងសង្គមខ្មែរ អ្នកកាន់ព្រះពុទ្ធសាសនានៅឡូវែល ក៏ដូចជានៅរដ្ឋផ្សេងទៀត ដែលធ្លាប់ល្អូកល្អិនស្រុះស្រួលមូលមតិគ្នាក្នុងការរក្សាការពារសាសនានឹងប្រពៃណីយ៍ជាតិរបស់យើង។

ថ្មីៗនេះជនកំជិលម្នាក់ដែលមានសំបកជាសង្ឃមានបេសកកម្មបង្រួបបង្រួមសហគមន៍ព្រះសង្ឃខ្មែរត្រូវបានព្រះចៅអធិការវត្តត្រៃរតនារាម ព្រះនាម សៅ ឃន ទទួលឱ្យស្នាក់នៅយ៉ាងកក់ក្តៅ ។ ថ្មីៗនេះដែរយើងឃើញព្រះតេជគុណ សៅ ឃន ស្រាក់ដៃគ្នាយ៉ាងតឹងជាមួយជនអាថ៌កំបាំងនេះ ដើម្បីច្រានចោលនូវពាក្យចោទប្រកាន់អំពីអំពើពុករលួយកេងប្រវ័ញ្ចលុយកាក់ និងអសីលធម៌ដែលបានកើតឡើងក្នុងជួរអ្នកដឹកនាំវត្តត្រៃរតនារាម។

យើងដឹងថា ព្រះអង្គនឹងជននោះបានផ្គុំខ្លួនគ្នាជាមុំចង្ក្រានបែរមុខចេញក្រៅ ដើម្បីទប់ទល់និងបញ្ហាដែលកំពុងឡោមព័ទ្ធដោយដាក់ស្រីម្នាក់នៅកណ្តាលដូចជាឆ្នាំងសម្លរការពារឆ្នាំនោះក្រែងរលំខ្ទាយសម្លរដែលមានរស់ជាតិដ៏សែនឆ្ងាញ់។

ព្រះតេជគុណ សៅ ឃន បានមានដីការថាអ្នកដែលនិយាយ បរិហា ម៉ាយ៉ា គឺព្រោះតែច្រណែនដោយខ្លួនឯងមិនមានសមត្ថភាពស្មើម៉ាយ៉ា របស់ព្រះអង្គព្រះអង្គបានបន្ថែមទៀតថា ម៉ាយ៉ា ឈ្លាសវៃ ហើយ "ខ្លាំង" បើមានមនុស្សដូចម៉ាយ៉ាពីរបីនាក់ថែមទៀតនោះកាន់តែល្អ។

ខ្ញុំគិតថា អ្វីដែលស្តែងច្វេមិនអាចឆ្លើយថា "ទេ" ដែលលោកអ្នកបានជ្រាបគ្រប់ៗគ្នារួចមកហើយនោះ សាក់សមល្មមធ្វើឱ្យ ឧបាសក ឧបាសិកា អ្នកមានជំនឿមុតមាំក្នុងព្រះពុទ្ធសាសនាអាចយកមកត្រិះរិះពិចារណាបានថា ស្ថានដែល ឧបាសក ឧបាសិកា ធ្លាប់សង្ឃឹមទុកចិត្តថា ជាស្ថានដែលអាចចម្លងបាននូវបុណ្យកុសលដែល ឧបាសក ឧបាសិកា កំពុងខំព្យាយាមសន្សំសំរាប់អនាគតជាតិ និងជាស្ថានដែលអាចដឹកនាំពាំយូរម្ហូបចំណីដែលឧបាសក ឧបាសិកា ខំផ្ចិតផ្ចង់ធ្វើជូនអស់លោកដែលបានចែកឋានទៅហើយនោះ តើជាស្ថានបែបណា?

ខ្ញុំជាអ្នកមានជំនឿលើព្រះពុទ្ធសាសនាម្នាក់ដែរ ខ្ញុំតែងតែរីករាយសប្បាយចិត្តនៅពេលដែលខ្ញុំរៀបចំម្ហូបចំណី "ចង្ហាន់" ទៅប្រគេនព្រះសង្ឃរួម និងប្រាក់កាសខ្លះសំរាប់បង្សុល និងកសាងទីអារាមសំរាប់ព្រះពុទ្ធសាសនាខ្ញុំគិតថា អ្នកដែលកោសក់ ហើយពាសខ្លួនដោយសំពត់ពណ៌លឿងដោយបានឆ្លងកាត់គ្រូឧបជ្ឈាយក្នុងផ្លូវពុទ្ធសាសនានោះ គឺជាអ្នកមានបុណ្យមានសីលធម៌ជាអ្នកបរិសុទ្ធជាអ្នកដែលអាចប្រាប់ព្រលឹងអ្នកដែលបានចែកឋានទៅហើយនោះថា ខ្ញុំបានកំពុងនាំយកម្ហូបចំណីមកថ្វាយជូនលោកហើយ ។

ចុះបើសិនណាជាអ្នកដែលយើងកំពុងគោរពទុកចិត្តក្នុងសីលទានបែរជាមនុស្សដែលគ្មាន សីល ខិលខូចល្មួចកីបកៀបរៀបល្បិច គេចពីភ្នែកចែកប្រាក់វត្តស្ទាត់ខាងផ្លូវតាមគុណថែមទៀតនោះមិនបានន័យថា ដែលយើងគ្រប់គ្នាខំផ្ចិតផ្ចង់តម្រង់ចិត្តធ្វើម្ហូបចំណីទៅប្រគេនព្រះសង្ឃប៉ះត្រង់ជនស្មោកគ្រោកទៅហើយទេឬ ? អ្វីដែលយើងខកចិត្តនោះ មិនមែនបាយសម្លនោះទេ ប៉ុន្តែគឺយើងត្រូវបានជនពីរបីនាក់នោះសើចចំអកឱ្យថា យើងជាពួកងាយកុហក...៕

# សេចក្តីអំពាវនាវចំពោះខ្មែរអ្នកស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោក

**ដោយ ស៊ាង ស័ក្ត**

យោងតាមសម្តីសមមិត្ត សោ ភីម កំពូល K.G.B កញ្ជះយួន ។ ដែលខ្ញុំស្តាប់ផ្ទាល់កាលពីដើមឆ្នាំ១៩៧៥ មុនរំដោះទីក្រុងភ្នំពេញ ។ បានឱ្យដឹងថា: អង្គការយើង ឬបក្សយើងប្រកាន់ខ្ជាប់នូវគោលជំហរនយោបាយជាយុទ្ធសាស្ត្របីយ៉ាងមាន ១-នយោបាយស្របច្បាប់ ២-នយោបាយបំបែកបំបាក់ដើម្បីគ្រប់គ្រង និង ៣-នយោបាយយកស្លឹកត្នោតស្ករត្រាប់ ។

នយោបាយយកស្លឹកត្នោតខ្ចប់ស្ករត្នោត : គឺនយោបាយយកខ្មែរឱ្យសម្លាប់ខ្មែរ ។ ឱ្យខ្មែរឈ្លោះប្រខាំប្រកាប់ប្រចាក់តែជាមួយខ្មែរហៅខ្មែររូបនីយកម្ម ។ នយោបាយបំបែកបំបាក់ ដើម្បីគ្រប់គ្រង : គឺនយោបាយបង្កប់បក្ខពួកខ្លួនឱ្យទៅធ្វើការបំបែកបំបាក់បក្សដទៃ ។ ដើម្បីឱ្យបក្សខ្លួនបានឱកាសគ្រប់គ្រងអំណាចក្នុងដៃតែម្នាក់ឯង ។ ចំណែកនយោបាយស្របច្បាប់ជានយោបាយឆ្លិនភ្នែកក្អែកក្នុងស្រោមហង្ស ដូចដែលកូនចៅបក្ខពួកសមមិត្ត សោ ភីម បាននឹងកំពុងធ្វើសព្វថ្ងៃនេះស្រាប់ ។

បញ្ហាសំខាន់ គឺកៅអីកម្ពុជានៅអង្គការសហប្រជាជាតិ ។ សមមិត្ត សោ.ភីម ថា ត្រូវដូរពីបក្សកុម្មុយនីស្តកម្ពុជាទៅបក្សសកកម្ពុជា ។ ហើយចូលសហព័ន្ធឥណ្ឌូចិនដែលមានវៀតណាមជារៀមច្បងស្របច្បាប់ជាតិ និងច្បាប់អន្តរជាតិទាំងស្រុង ។ ពោលគឺឱ្យតែយើងកាន់កាប់កៅអីកម្ពុជានៅអង្គការសហប្រជាជាតិជាមូលដ្ឋានបានហើយ ។ គឺអ្វីៗត្រូវតែចប់ហើយ ។

ឥឡូវនេះអស់ពីសម្តេចសីហនុហើយ ។ ចរន្តនីនយោបាយជាយុទ្ធសាស្ត្ររបស់យួនទាំងបីយ៉ាងតាមរយៈបក្ខពួកកូនចៅសមមិត្ត សោ. ភីម ផ្ទាល់ដូចគេថា ឆ្កែចេះតែព្រូសមនុស្សចេះតែដើរទៅមុខនោះហើយ ។ ដើម្បីជាជំនួយជួយទប់ស្កាត់ឱ្យបានទាន់ពេលវេលា សូមជូនវិភាគសេចក្តីអំពាវនាវដូចតទៅ :

**ទី១-** មកដល់ពេលនេះបងប្អូនមិនត្រូវធ្វើការម្នាក់ឯងទេ ។ តែបងប្អូនត្រូវពឹងកម្លាំងអន្តរជាតិទាំងពីរ គឺតុលាការអន្តរជាតិ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសខ្ជាប់ខ្ជួនឥតងាករេឥតរេទៅខាងទីទៃ ។

**ទី២-**ចំពោះបងប្អូននៅឯប្រទេសបារាំង ។ សូមបងប្អូនធ្វើអន្តរាគមន៍តាមញត្តិក្តីបាតុកម្មក្តី ។ ដើម្បីតស៊ូទាមទារស្នើសុំដោយទទូចម្តងហើយម្តងទៀត ។ ដល់ប្រទេសបារាំងដែលជាសហប្រធាន ។ រហូតដល់មានការអនុវត្តន៍ត្រឹមត្រូវតាមកិច្ចព្រមព្រៀងប៉ារីស ។

**ទី៣-** ចំពោះបងប្អូននៅសហរដ្ឋអាមេរិកកាលណាជាយើងនេះ ។ សូមបងប្អូនធ្វើអន្តរាគមន៍តាមញត្តិក្តីតាមបាតុកម្មក្តី ។ ដើម្បីតស៊ូទាមទារស្នើសុំដោយទទូចដល់អង្គការសហប្រជាជាតិ ។ ឱ្យលោកដាក់ទង់ពីឆ្នាំ១៩៩៣ ដែលមានរូមកម្ពុជាជំនួសវិញ ។ ដើម្បីបើកផ្លូវឱ្យមានការអនុវត្តន៍កិច្ចព្រមព្រៀងប៉ារីស ។ មិនត្រូវទុករបបរាជាណាចក្រកម្ពុជាទីពីរក្បត់កិច្ចព្រមព្រៀងប៉ារីស ។ ឱ្យកម្លាំងបរទេសឈ្លានពានគ្រប់ប្រភេទយកធ្វើជម្រក ។ សម្រាប់ជ្រកពួនសម្លាប់បំផ្លាញខ្មែរទៀត ។

ទី៤-យើងមិនកាន់នយោបាយឈ្នះៗ ។ តែយើងកាន់នយោបាយត្រូវៗ ។ របបរាជានិយមក្បត់កិច្ចព្រមព្រៀងប៉ារីសរបស់សម្តេច សីហនុ គឺសម្តេចសីហនុសោយរាជ្យអត់មានអំណាច ។ ទោះបីដាក់រាជ្យឱ្យអ្នកណានៅក៏នៅតែអត់មានអំណាចដែរ ។ សីហមុនី និងអ្នកម្នាង ម៉ូនិច ពីរនាក់ម៉ែកូនមិនបាច់នៅធ្វើស្តេចតុក្កតា **តទៅទំព័រទី ០៥**

# រឿងបែកបាក់សាមគ្គីនៃវត្តសុរិយុរង្សី វិវត្តដល់ណាហើយ?

**ដោយ: គីម ភឿន**

**ហ៊្វីឡាដែលហ្វៀ :** សរសេរចេញពី Richmond ,Vingivia ពីម្សិលមិញថ្ងៃសៅរ៍ទី៦ មេសា ខ្ញុំបានទូរស័ព្ទពីឧសិកា សឺន ធីរិត ថារឿងវិវាទរវាងក្រុមទាំងពីរ គឺក្រុមជាប់ឆ្នោតដឹកនាំដោយលោកប្រធានគណកម្មការថ្មីនឹងលោកអ្នកខាងក្រុមកម្មការចាស់មានឧបាសិកា វេន ជាប្រធានបានស្រុះស្រួលគ្នាឈប់ចោទប្រកាន់គ្នាទៀត ហើយថានឹងនាំគ្នាម្ខាង៥នាក់មករួបរួមគ្នាដោះស្រាយជួយចាត់ចែងគ្នាធ្វើបុណ្យចូលឆ្នាំរួមគ្នាដោយសុខដមរមនាដោយបំបាត់ចោលអរិយភាពទាំងឡាយ ។ នេះជាការប្រែប្រួលមួយដ៏ល្អប្រពៃណាស់ សូមសរសើរបងប្អូនយើងទាំងពីរក្រុមដែលមានគតិបណ្ឌិតនេះ ។ តែនេះគ្រាន់តែជួបគ្នាតាមទូរស័ព្ទប៉ុណ្ណោះទេ សន្យាថា ជួបមុខគ្នាដោយស្រាយនៅថ្ងៃសៅរ៍ម្សិលមិញនេះ។



ថ្ងៃនេះគឺថ្ងៃអាទិត្យទី៧មេសា ឧបាសិកា សឺន ពិនិត្យបានឆ្លើយនឹងទូរស័ព្ទខ្ញុំកាលពីម៉ោង៨យប់ថា មិនមានជួបមុខគ្នាតែលោក ង៉ោ ថាច់ង៉ុក ជាប្រធានជាប់ឆ្នោតបានជម្រាបតាមទូរស័ព្ទមកថា (ក្រុមគាត់មានយោបល់ថា គ្រាន់តែធ្វើបុណ្យចូលឆ្នាំប៉ុណ្ណឹងមិនចាំបាច់គ្នាដល់ទៅ១០នាក់រៀបចំដោះស្រាយអីទេ ប្រគល់ជូនព្រះសង្ឃទាំងពីរព្រះអង្គដែលគង់នៅក្នុងវត្តនោះ លោកចាត់ចែង ហើយយើងទាំងអស់គ្នានាំគ្នាទៅវត្តរួមគ្នាទៅបានហើយ ។

ហេតុនេះរឿងប្តឹងបួល់គ្នារឿងដេញព្រះសង្ឃចេញពីវត្តជារឿងយល់សប្តិអាក្រក់ និងដ៏សែនចង្រៃនោះបានអហោសិកម្មទៅតាមរលកនៃឆ្នាំថ្មី គឺឆ្នាំម្សាញ់បញ្ចសក្តិនេះបាត់ទៅហើយ ។

នេះជាដំណឹងដែលធ្វើឱ្យលោកអ្នកសរសេរដំណឹងពី (រីក ឆ្អិន) មានវ័យចាស់ចំណាស់៧៤ឆ្នាំ ភ្នែកអន់ បេះដូងញាប់ញ័រ អួលណែន ដោយតក់ស្លុតភ័យខ្លាចបងប្អូនរួមឈាមប្តឹងប្តល់គ្នាឯងបានបណ្តេញបំបង់ព្រះសង្ឃនោះបានជូតទឹកភ្នែកឱ្យស្ងួត ហើយសូមជូនពរដោយបេះដូងស្រស់ស្រាយរំភើបឱ្យបងប្អូនទាំងអស់គ្នាបានសុខសប្បាយបានសន្តិភាពនឹងបានរួចពីទុក្ខខ្ចោះខ្សៀងនៃលោកនេះតាំងពីឆ្នាំម្សាញនេះតរៀងទៅកុំបីឃ្លៀងឃ្លៀតឡើយ ហើយសូមបងប្អូនទាំងពីរក្រុមមេត្តាទទួលនូវក្តីកោតសរសើរដ៏ស្មោះរបស់មនុស្សចាស់ម្នាក់នេះ នៅអ្នកទាំងអស់គ្នាជាវីរៈបុរសដែលបានលះបង់ចោលនូវឥទ្ធិពលមានរៀងខ្លួន ដើម្បីសាមគ្គីភាពមួយដ៏យូរអង្វែងបងប្អូនរួមឈាមរបស់ខ្លួនបានប្រារព្ធពិធីចូលឆ្នាំមួយដ៏សែនរីករាយនឹងជោគជ័យរួម។ កាលពីមុនខ្ញុំបានហូរទឹកភ្នែក ហើយសរសេរថា :

ឱទ្រសោខ្មែរដាច់ខ្សែហើយស្ពានមេត្រីអើយ បាក់បង្ហូរទឹកភ្នែកចាស់នេះសច្ចាផ្សងសូមឱ្យបង្គងតភ្ជាប់វិញ ! ។

ឥឡូវនេះមនុស្សចាស់សរសេរវិញថា :

តាចាស់នេះសែនសប្បាយក្រៃការអ្នកវិនិច្ឆ័យប្រសើរហោង ខ្ញុំសុំគោរពលើកតម្កើងពពកខ្មៅខ្ចាត់ប៉ើងដោយសារអ្នក៕ *ដោយ : បញ្ញា សីលា*

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន



និពន្ធដោយ ឡឹក សំអឿន ហៅ "ថ្កាយព្រឹក"

ត្រឡប់ទៅជាការស្មានខុសទាំងស្រុងទៅវិញ ព្រោះបារាំងបានពង្រីកអំណាចខ្លួនដែលជាអាណាព្យាបាលឱ្យទៅជាអាណានិគមនិយមលើប្រទេសខ្មែរទៅវិញ។ មិនតែប៉ុណ្ណោះជាច្រើនលើកច្រើនគ្រាបារាំងបានពុះដីទឹកកម្ពុជាយ៉ាងច្រើនក្រៃលែងឱ្យទៅសៀម និងឱ្យទៅយួន ដោយឥតមានឱ្យដំណឹងដល់ខ្មែរជាម្ចាស់ទឹកដីជាមុនសោះឡើយ ។ តើត្រង់នេះហើយឬ ដែលអ្នកនិពន្ធបារាំងសរសេរថា "ជនជាតិខ្មែរជាមនុស្សដែលគេស្រណុកបញ្ឆោត ហើយគ្មានប្រតិកម្ម"នោះ ?

សម្តី ប៉ូល ឌូមែរ អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ដែលគាត់ចង់និយាយថា ជនជាតិខ្មែរដែលរស់នៅក្នុងកម្ពុជាសព្វថ្ងៃមិនមែនជាពូជសាសន៍អង្គរទេនោះ ជាជនជាតិខ្មែរដែលរស់នៅក្នុងកម្ពុជាសព្វថ្ងៃ មិនមែនជាពូជសាសន៍ខ្មែរអង្គរទេនោះ វាជាសម្តីប្រមាថមើលងាយខ្មែរខ្លាំងណាស់ ជាសម្តីមនុស្សពាល ដែលពោរពេញទៅដោយអវិជ្ជមាន និងអគតិធមិជាជនថោកទាបដែលឈ្លក់ក្នុងនយោបាយស្រីស្រស់ស្រុកយួនសុទ្ធសាធ ។ គាត់នេះ កើតមកមានឈ្មោះថា "ឌូមែរ"ដែលជាពាក្យសម្រាប់ឱ្យយួនដែរ ។ ជនជាតិបារាំងក្នុងឋានៈខ្លួនជាជាតិមួយដែលបានធ្វើបដិបដិវត្តន៍ ដើម្បីបំបាត់អំពើមនុស្សជិះជាន់មនុស្សនោះ តើបានធ្វើអ្វីខ្លះដល់ប្រទេសដែលខ្លួនបានត្រួតត្រា? អ្នកអានគង់នឹងឃើញអំពើលាមកបារាំងនៅវគ្គក្រោយៗ។

## វគ្គទី៣

## នយោបាយបារាំងនៅកម្ពុជា

ជាដំបូង ដើម្បីឱ្យងាយស្រួលក្នុងការនាំយកអ្នកបំរើជាជនជាតិយួនដែលមានចំណេះវិជ្ជាមានប្រាជ្ញាឈ្លាសវៃ និងជាមនុស្សដែលខ្លួនទុកចិត្តឱ្យចូលមកធ្វើការនៅកម្ពុជាក្នុងក្របខណ្ឌឱ្យមើលការខុសត្រូវលើអ្នកបំរើល្ងង់ខ្លៅ(ខ្មែរ) ដែលប្រើតែកម្លាំងបាយនោះ ព្រមទាំងឱ្យបណ្តាជនយួនដែលរស់នៅតាមជាយដែនខ្មែរចូលមករស់នៅក្នុងទឹកដីខ្មែរបានដោយងាយនោះ បារាំងបានបង្កើតជា "សហ-ភាពឥណ្ឌូចិន"មួយដោយបានបំបាត់ចោលនូវព្រំប្រទល់ទឹកដីរវាងប្រទេសខ្មែរ និងប្រទេសយួន ។ ប្រទេសទាំងពីរបានត្រូវបារាំងបញ្ចូលគ្នាឱ្យទៅជារដ្ឋតែមួយតាមផ្លូវច្បាប់ដែលមានក្រឹត្យចុះថ្ងៃទី១១ វិច្ឆិកា ១៨៨៧ ឱ្យឈ្មោះថា "សហភាពឥណ្ឌូចិនបារាំងសែស"។ កាលនោះប្រទេសលាវពុំទាន់នៅក្រោមអាណាព្យាបាលរបស់សៀម ឯនគរសៀងក្វាង និងខាំមួនឋិតនៅក្រោមការត្រួតត្រារបស់យួន ។

នៅលើរដ្ឋថ្មីនេះ មានអគ្គទេសាភិបាល (Gouvemeur-genral) ជាជាតិបារាំងម្នាក់កាន់អំណាចទាំងអស់ ហើយឋិតនៅក្រោមរដ្ឋមន្ត្រីក្រសួងអាណានិគមនៅឯប្រទេសបារាំងឯណោះ ។ អគ្គទេសាភិបាលជាអ្នកចាត់ចែងកិច្ចការនៅឥណ្ឌូចិនបារាំងទាំងមូលជាមួយមេដឹកនាំជាជនជាតិបារាំង៤នាក់ គឺ:

១-ទេសាភិបាល (Gouvemeur) ម្នាក់ប្រចាំនៅកូសាំងស៊ីន

២-រ៉េស៊ីដង់ត៍ស៊ុបេរីយើម្នាក់ប្រចាំនៅកម្ពុជា

៣-រ៉េស៊ីដង់ត៍ស៊ុបេរីយើរម្នាក់ប្រចាំនៅអណ្ណាម

៤-រ៉េស៊ីដង់ត៍ស៊ុបេរីយើរម្នាក់ប្រចាំនៅតុងកឹង។

ឯស្តេចទាំងឡាយនៃប្រទេសនីមួយៗអំណាចមានតែនៅលើក្រដាសប៉ុណ្ណោះ ។ ការបែងចែករដ្ឋបាលនៃប្រទេសនីមួយៗ មានជាអាទិ៍ គឺខេត្តនីមួយៗ មានរ៉េស៊ីដង់ត៍ជាជាតិបារាំងម្នាក់ជាអ្នកត្រួតត្រាគ្រប់មុខក្រសួងក្នុងខេត្ត,ស្រុក,ខណ្ឌ និងឃុំ ហើយមានមេតម្រួតឃោបារាំង១នាក់ហៅថា "ហ្សង់ដាម"(Gendamme) ជាអ្នកត្រួតត្រាមើលការខុសត្រូវ ។ ក្រោយមកគេលុបខណ្ឌចោល រួចហើយមុខងារចៅហ្វាយខេត្តក្តី, ចៅហ្វាយស្រុកក្តី, មេឃុំក្តីត្រូវបានគេបង្កើតឡើងនៅប្រទេសខ្មែរក្នុងរវាងគ.ស ១៩១៥ ។

ប៉ុន្តែការបង្កើតសហភាពឥណ្ឌូចិននេះ មានតែនៅក្នុងក្រដាសប៉ុណ្ណោះទាល់តែ១០ឆ្នាំ ក្រោយមក ទើបអង្គការផ្សេងៗ មានដំណើរពិតប្រាកដក្នុងរជ្ជការរបស់លោក ប៉ូល ឌូមែរ ដែលជាអគ្គទេសាភិបាលនៃសហភាពឥណ្ឌូចិន ពីគ.ស ១៨៩៧-១៩០២ដែលមានទីសំណាក់ការដំបូងបង្អស់នៅហាណូយ ។ ឯភ្នាក់ងារបំរើកិច្ចការទាំងអម្បាលម៉ាន ក្រៅពីអ្នកទទួលខុសត្រូវមុខក្រសួង និងមេផ្នែកខ្លះៗដែលជាជនជាតិបារាំងនោះ គឺសុទ្ធតែជាជាតិយួនទាំងអស់ ។ នៅក្នុងប្រទេសនីមួយៗដែលបែងចែកជាខេត្តនោះ តំណែងរ៉េស៊ីដង់ត៍មេផ្នែកសាធារណការ, មេផ្នែកសុរិយោដី, មេផ្នែកសុខភិបាល , មេផ្នែកសិក្សាធិការ , មេគយ , មេផ្នែកសន្តិសុខ, មេផ្នែកយោធា, មេផ្នែកឃ្លាំងសុទ្ធតែជាជន ជាតិយួនទាំងអស់ ។ មានខេត្តខ្លះដែលនៅចាប់ព្រំដែនខ្មែរ-យួន សូម្បីតែមេផ្នែកសាធារណការ, មេផ្នែកសុរិយោដី និងមេផ្នែកសុខភិបាល ក៏សុទ្ធតែជាសាសន៍យួនដែរ ។ តទៅលេខក្រោយ

NEW ENGLAND INSTITUTE OF HVAC, Inc.
វិទ្យាស្ថានញូអិនគ្លិនជំនាញខាងបង្រៀនពី
ម៉ាស៊ីនកំដៅ, ម៉ាស៊ីនត្រជាក់ និងទូរទឹកកក
ថ្នាក់រៀនពេលថ្ងៃ និងពេលល្ងាច និងផ្តើមឆាប់ៗនេះ
បំពេញការសិក្សាបច្ចេកទេសខាងម៉ាស៊ីនត្រជាក់
ម៉ាស៊ីនកំដៅ ទូរទឹកកក HVAC គឺសិក្សា
តែរយៈពេល១៣សប្តាហ៍
• សិក្សាដោយពិសោធន៍ផ្ទាល់ដៃ • ជួយរកការងារធ្វើ
• ផ្តល់សម្ភារៈឱ្យ • ថ្នាក់រៀនសិស្សតិច
• GI Bill Education Benefits Approved
• Section 30 Approved



NATE Certifications, EPA Testing, OSHA, and Financing Available to those who qualify
គឺជាប្រភពសម្រាប់ថាមពលបៃតង
Call for details: 978.735.4979
NEW ENGLAND INSTITUTE OF HVAC, INC
240 Smith St., Lowell, MA 01851
www.newenglandhvac.com

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
• សេចក្តីគ្រោះថ្នាក់ដល់រូបរាងកាយ
• ពិការភាពដោយសន្តិសុខសង្គម • គ្រោះថ្នាក់ចរាចរណ៍
• បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន • គ្រោះថ្នាក់នៅការដ្ឋាន
• ច្បាប់គ្រួសារ និងលែងប្តីប្រពន្ធ
• បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
• Personal Injury • Family Law & Divorce
• Disability • Traffic Accidents
• Sex & Drug Crimes, OUI • Work Accidents
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

# មេធាវីថីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

# Red Rose RESTAURANT

ភោជនីយដ្ឋាន កុលាបក្រហម

ម្ចាស់ថ្មី _ម្ហូបឈ្ងុយឆ្ងាញ់

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm





សម្លម្ជូរ គ្រឿង $11.99







* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

**(978) 452-5400**

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

# ហាងមាស គីម ង៉ុក នៅវេសហាតហ្វឺត




មានលក់ដុំ ឬរាយ ឬដូរ ឬធ្វើប័ណ្ណសំរាប់
អំណោយមានធ្វើប្លែនពន្យាពេលបង់ប្រាក់
-ទទួលតវ៉ាន់បញ្ញើ មានចុះថ្លៃរហូតដល់ ៦៥%
សម្រាប់ ពេជ្រមកពីហុងកុង មានជាងអលង្ការ
នៅក្នុងហាងជួសជុលបានភ្លាមៗ
**ពេលវេលាបើក :** ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ
ពីម៉ោង ១០ព្រឹកដល់៧ល្ងាច



Open: Mon-Sun:
10am-7pm

150 Shield Street Plaza. West Hartdord, CT 06110
Tell: (860) 953-5803, Fax:(860)953-5802

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE
978-596-1111

**345 Chelmsford St. Lowell, MA 01851/ 978-596-1111 – www.lowelleldercare.com**

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips



**សូមហៅទៅលោក វង្ស រស 978 996 6127**

តមកពីទំព័រទី ១

## សម្ភាសន៍ជាមួយលោក សម រង្ស៊ី ស្តីពី...

ដែលទើបបង្កើតឡើង កាលពីថ្ងៃទី៧ មេសាកន្លងទៅដោយការរំលាយចូលគ្នា រវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សទាំងពីរជាគណបក្សមាននិន្នាការប្រជាធិបតេយ្យសេរីប្រឆាំង និងគណបក្សប្រជាជនដែលកំពុងដឹកនាំរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ។ បន្ទាប់ពីចូលរួមជាគណធិបតីនៃពិធីជប់លៀងដ៏ត្រចះត្រចង់មានសាធារណជនចូលរួមប្រមាណ៤០០នាក់ លោក សម រង្ស៊ី បានផ្តល់បទសម្ភាសន៍ដល់កាសែតខ្មែរផុសស.រ.អាដូចតទៅ :

**ពិន សំខុន :** សូមអរគុណលោក សម រង្ស៊ី ដែលបានផ្តល់ឱកាសឱ្យយើងធ្វើសម្ភាសន៍ផ្តល់ព័ត៌មានចែកជូនសាធារណជននៅឆ្នេរខាងកើត ស.រ.អា នេះ សំនួរដំបូង តើលោកយល់ថា គណបក្សសង្គ្រោះជាតិកើតឡើងពីការរំលាយចូលគ្នា រវាងគណបក្សប្រឆាំង២ ដោយភាពរលូន ចុះសម្រុងគ្នា ឬក៏មានភាពរកាំរកូសដែរ ?

**សម រង្ស៊ី:** ឥតមានបញ្ហាអីគួរឱ្យកត់សំគាល់ទេ ពីព្រោះកាលពីសមាជថ្ងៃទី៧ មេសានេះគណបក្សសង្គ្រោះជាតិមានតំណាងភូមិក្រុង១ម៉ឺននាក់ មានទាំងអ្នកសង្កេតការណ៍ចូលរួមផងដែរ បានបង្កើតរចនាសម្ព័ន្ធបង្កើតលក្ខន្តិកៈច្បាប់ទម្លាប់ផ្សេងៗ ដោយការយល់ព្រមពីសមាជមានភាពរលូនគ្មានបញ្ហាអីទេ



**ពិន សំខុន :** នៅប៉ុន្មានខែខាងមុខនេះ និងមានការបោះឆ្នោតជាតិលោក សម រង្ស៊ី ដែលជាប្រធាននៅក្រៅប្រទេសមានការទស្សន៍ទាយរបស់អ្នកវិភាគកាលពីពេលមុនៗនិយាយថា "ការគាំទ្រចំពោះគណបក្ស សម រង្ស៊ី និងចុះថយ" តើស្ថានភាពថ្មីឥឡូវនេះ ជាមួយគណបក្សសង្គ្រោះជាតិលោកនៅក្រៅប្រទេស ឬចូលក្នុងប្រទេសបានវិញ នឹងមានអ្វីផ្លាស់ប្តូរ ?

**សម រង្ស៊ី :** គណបក្សសង្គ្រោះជាតិជាចលនាប្រជារាស្ត្រខ្មែរ ដែលប្តេជ្ញាចិត្តសង្គ្រោះជាតិមាតុភូមិរបស់ខ្លួន បើមានតួរនាទីបេសកកម្មធំយ៉ាងនេះ គឺមិនមែនតែ សម រង្ស៊ី ម្នាក់ឯងធ្វើបាននោះទេ គឺជាស្នាដៃពលរដ្ឋរាប់សែនរាប់លាន ទើបធ្វើបាន បើថាខ្ញុំជាតំណាងឱ្យឧត្តមគតិ សម រង្ស៊ី ហើយឧត្តមគតិនេះស្ថិតនៅក្នុងចិត្តពលរដ្ឋខ្មែររាប់លាននាក់ ដូច្នេះដំណើរការណ៍នៃគណបក្សមិនអាស្រ័យវត្តមាននៃ សម រង្ស៊ី តែម្នាក់នោះទេ ។ ស្ថានភាពសព្វថ្ងៃនៃការបោះឆ្នោតនៅកម្ពុជាត្រូវការឱ្យខ្ញុំធ្វើការលើឆាកអន្តរជាតីដាក់គំនាបលើរដ្ឋាភិបាលលោក ហ៊ុន សែន ដើម្បីឱ្យមានការរៀបចំការបោះឆ្នោតឱ្យបានត្រឹមត្រូវកម្លាំងពលរដ្ឋទាមទាររយ៉ាងណាមិនទាន់បានសម្រេចទេ ទាល់តែដង្ហាបមកពីអន្តរជាតិព្រមានលោក ហ៊ុន សែន និងគណបក្សប្រជាជនដែលកាន់អំណាចសព្វថ្ងៃ ថាបើខ្លួនមិនធ្វើតាមទេនោះ នឹងទទួលផលវិបាកយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះទាល់តែយើងមានវត្តមានលើឆាកអន្តរជាតិ ទើបយើងបង្កើនលទ្ធភាពជម្រុញឱ្យមានការបោះឆ្នោតមានតម្លាភាពកុំឱ្យមានការលួចបន្លំសន្លឹកឆ្នោតដូចមុនទៀតបាន ។

**ពិន សំខុន :** លោក ហ៊ុន សែន និងគណបក្សប្រជាជនមិនដែលញញោច និងការគម្រាមកំហែងរបស់សហគមន៍អន្តរជាតិម្តងណាទេ តើពេលនេះលោកមានសញ្ញាអ្វីថ្មី ទើបអាចសន្និដ្ឋានថាលោក ហ៊ុន សែន និងស្តាប់សហគមន៍អន្តរជាតិ ?

**សម រង្ស៊ី :** ដោយសារយួនមិនឱ្យខ្ញុំ មានវត្តមានក្នុងការបោះឆ្នោតនៅកម្ពុជាដែលខ្ញុំហ៊ានចេញមុខប្រឆាំង និងយួនបានប្រើដៃគណបក្សប្រជាជនធ្វើឱ្យខ្ញុំខ្ចាតចេញយ៉ាងនេះ តែមិនមែនជាលើកទី១ទេ ច្រើនដងហើយដែលគេរករឿងខ្ញុំបែបនេះមកកាត់ទោសខ្ញុំដែលគេប្រើតុលាការឡប់ឡែបង្ខំឱ្យខ្ញុំនិរទេសខ្លួន ចុងបញ្ចប់មានដំណោះដូចគ្នា ពុំមែនគេចិត្តល្អអីទេ តែសម្ពាតអន្តរជាតិទើបខ្ញុំអាត្រឡប់មកចូលរួមការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០០៧បាន ឥឡូវឆ្នាំ២០១៣ក៏អ៊ីចឹងដែរ... ងាកទៅមើលឆ្នាំ២០០៧ បន្ទាប់ពីរដ្ឋប្រហាររូបខ្ញុំក៏ត្រូវបង្ខំខ្លួនឱ្យចេញក្រៅប្រទេសសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ក៏អ៊ីចឹងដែរ ប៉ុន្តែដោយសារសម្ពាតនៃអន្តរជាតិ អ.ស.ប.បានធ្វើជាស្ពានឱ្យយើងត្រឡប់ទៅចូលរួមបោះឆ្នោតវិញបាន គេប្រើតុលាការអីដូចគ្នាអញ្ចឹង សូម្បីតែសម្តេចសីហនុ កាលពីធ្វើចលនាតស៊ូហ្នឹងក៏តុលាការភ្នំពេញហ្នឹងកាត់ទោសលោកឱ្យជាប់គុកមួយជីវិតដែរ តែសម្តេច សីហនុ មានឱ្យយួនចាប់ឯណាតែចាប់បានចលនាតស៊ូមិនអាចទៅមុខបានទេ ត្រូវច្បាំងជាមួយយួនគ្រប់រូបភាពមិនត្រូវតក់ស្លុត និងតុលាការភ្នំពេញទេ ហើយដោយសារសម្ពាតអន្តរជាតិនោះឯង ទើបមានកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១

តទៅលេខក្រោយ






តមកពីទំព័រទី ១១
## ចូលឆ្នាំខ្មែរនៅ"វត្តសហគមន៍...

បានលើកបដារពេញមួយព្រឹកបង្ហាញការថ្កោលទោសចំឈ្មោះចំពោះរឿងអាស្រូវដែលគេជឿថាបានកើតឡើងនៅក្នុងវត្ត រវាងព្រះសង្ឃព្រះនាម ញែម គិមតេង ជាមួយនឹងស្ត្រីអ្នកជំនួយការវត្តឈ្មោះ ម៉ាយ៉ា ម៉ែន ដែលនៅក្រោមការគ្រប់គ្រងរបស់ព្រះគ្រូចៅអធិការ សៅ ឃន ។ បាតុកម្មនេះបានរាំងស្ទះពុទ្ធបរិស័ទខ្មែរដែលគណកម្មាការវត្តគេគ្រោងទុកថា មានចំនួនយ៉ាងហោចក៏៥០០នាក់ដែរ និងមកធ្វើបុណ្យចូលឆ្នាំពូនភ្នំខ្សាច់នៅ"អាល់ក្លឹប"នេះ បែរជានៅសល់តែប្រមាណ២០ភាគរយប៉ុណ្ណោះ។









បាតុករលើកបដារ និងស្រែកអាក្រោសនៅមួយចំហៀងផ្លូវ រីឯពិធីបុណ្យស្ថិតនៅមួយចំហៀងទៀត នៅកណ្តាលមានកងប៉ូលិសរក្សាសន្តិសុខច្រើនរូបបានរារាំងមិនឱ្យបាតុករ ឬរថយន្តបើកចូលក្នុងរង្វង់ពិធីបុណ្យក្រៅពីមានករណីចាំបាច់ឡើយ ។ លើកនេះបាតុករមានចំនួនច្រើនជាងអ្នកមកធ្វើបុណ្យដោយសារបាននាំគ្នាគ្រោងសកម្មភាពខ្លួនតាំងពី២ថ្ងៃមុន គឺកោះហៅគ្នាមកប្រជុំពិភាក្សានៅភោជនីយដ្ឋានសានីដាអំពីកំហឹងសហគមន៍ចំពោះរឿងអាស្រូវចេញពីទង្វើដែលសង្ឃមិនត្រូវធ្វើនៅក្នុងវត្តសហគមន៍ព្រះសង្ឃខ្មែរ ហើយនិងភ្ជាប់កំហឹងលើអធិការដែលសហគមន៍មានជាមួយរឿងនៅវត្តត្រៃរតនារាម"វត្តលើវត្តក្រោម" តាំងពីជាង១២ឆ្នាំមកទល់ថ្ងៃនេះ ។ ចំណែកខាងព្រះគ្រូ សៅ ឃន វិញ បន្តធ្វើពិធីសូត្រមន្តពីមួយទៅមួយយ៉ាងស្ងាត់ជ្រងំដោយពុំមានឃើញវត្តមានមនុស្សសំខាន់របស់វត្ត គឺព្រះសង្ឃ ញែម គិមតេង ឬអ្នកជំនួយការ ម៉ាយ៉ា ម៉ែន ដូចសព្វមួយដងជាមួយគ្នានោះក៏មានបំរាមមិនឱ្យនរណាសួរនាំពីរឿងអាស្រូវដល់លោកគ្រូចៅអធិការក្នុងឱកាសធ្វើពិធីបុណ្យចូលឆ្នាំថ្មីឡើយ ។ ជារួមសហគមន៍ខ្មែរនៅក្បែរបរិវេណ"វត្តសហគមន៍ព្រះសង្ឃខ្មែរ" ឬ "វត្តខ្មែរឡូវែល"ទាំងអស់ប្រមាណជា២០០នាក់នាំគ្នាបង្ហាញភាពខឹងសម្បារខាងក្រៅ "អាល់ក្លឹប" ខាងក្នុងនាំគ្នាធ្វើបុណ្យចូលឆ្នាំយ៉ាងអណោចអធម្ម បើកុំតែមានកងរក្សាសន្តិសុខអធិការអាចនឹងឈានទៅរកការចូលទៅអុកឡុក ឬវាយតប់គ្នាបាន ។

ទាំងសងខាងសុទ្ធតែជាមនុស្សថ្នាក់ដឹកនាំធ្លាប់ស្គាល់គ្នាតែពុំមានបំណងជួបគ្នា ដើម្បីសំដែងតម្លាភាពក្នុងការរកដំណោះស្រាយត្រជាក់តែងបង្ហាញកំហឹងលើភាពអាមាសតែងចង្អុលមុខរកអ្នកខុសជាមនុស្សដ៏ទៃច្រើនជាងហានប្រឈមយកការពិតប្រឈម និងភាពសុច្ចរិត។ តាមរយៈបដារគេអាចយល់បានថា ក្រុមបាតុករថ្កោលទោសអំពី ១-អាចមានមនុស្សពុករលួយលួចលុយវត្ត ២-មានលោកសង្ឃដាច់សីលនៅក្នុងវត្ត ហើយដោយឡែកក្រុមមួយផ្នែកទៀត តាមរយៈមនុស្សជំនិតរបស់វត្តថា ១-អ្នកចែកផ្សាយថាសកុនកូនជ្រូកដែលមិនពិតជាអ្នកខុស ២-ទង្វើរបស់សង្ឃមានតែព្រះសង្ឃទេ ជាអ្នកដោះស្រាយ ៣-រឿងលុយវត្តក៏គេមានគណកម្មការជាព្រះសង្ឃរួចហើយដែរ មិនចាំបាច់អ្នកក្រៅមកជួយទេ។ ការបិតទ្វារមិនឱ្យមានដំណោះស្រាយទល់មុខបណ្តាលឱ្យមានផ្ទុះការប្រមូលប្តុំសមាជិកសហគមន៍ដែលមិនពេញចិត្តនឹងទង្វើរបស់ "វត្តសហគមន៍សង្ឃខ្មែរ" ជាថ្មីម្តងទៀត ។

កិច្ចប្រជុំក្រុមបាតុករនៅភោជនីយដ្ឋានសានីដា ថ្ងៃអាទិត្យទី២១មេសា២០១៣ វេលាម៉ោង១១ថ្ងៃត្រង់ កិច្ចប្រជុំមានមនុស្ស៥-៦០០នាក់ចូលរួមដោយគ្មានការអញ្ជើញបានមកសម្តែងការខឹងសម្បារចំពោះព្រះគ្រូចៅ អធិការ សៅ ឃន ដែលមិនបានឆ្លើយតបនឹងសំណូមពរប្រជាពលរដ្ឋជាពុទ្ធបរិស័ទខ្មែរនៅទីក្រុងឡូវែល ហើយការពារលាក់បាំងសង្ឃបរាជិក ញែម គិមតេង និងនាង ម៉ាយ៉ា ម៉ែន ថែមទៀត ។ ក្នុងអង្គប្រជុំដឹកនាំដោយ រ៉ាឌី ម៉ម និង សែម មាស មានគណធិបតីលោក វ៉ាស្នា នួន សមាជិកគណក្រុមប្រឹក្សាក្រុងឡូវែលប្រធានសមាគមខ្មែរ រ៉ាស៊ី អាន អគ្គកុងស៊ុល កិត្តិយស អ៊ូ សាវណ្ណ អតីតក្រុមប្រឹក្សាក្រុងរីទ្ធី អ៊ុង ។ល។ តទៅទំព័រទី ២០

តមកពីទំព័រទី ១
## Season of Cambodia ព្រឹត្តិការណ៍...

និងសម្តែងរបាំបុរាណរបាំសហសម័យ ចាប៉ីដងវែង ការតាំងពិពរណ៍រូបភាព និងភាពយន្តមានជាអាទិ៍ក្បង់ទឹកទន្លេ របាំព្រះរាជទ្រព្យ ល្ខោនស្បែក ព្រមទាំងសិល្បៈប្រសូត្រចេញពីគំនិតច្នៃប្រឌិតរបស់កូនខ្មែរជាច្រើនទៀត ។ គម្រោងនេះធំ ហើយចំណាយទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ជាង២,៥លានដុល្លារសហរដ្ឋអាមេរិក ។ ក្នុងឱកាសដ៏កម្រនេះសារព័ត៌មានខ្មែរផុស និងផ្តល់ជូននូវព័ត៌មានសំខាន់ៗទាក់ទងទៅនឹងបេសកកម្មរបស់ Season of Cambodia ព្រមទាំងវត្តមាន



ភ្នាក់ងារព័ត៌មានខ្មែរផុស ស.រ.អា បានចំណាយពេលជិតកន្លះខែ ដើម្បីចុះយកព័ត៌មានដោយផ្ទាល់ទាក់ទិនទៅនឹងព្រឹត្តិការណ៍ Season of Cambodia ដែលប្រព្រឹត្តិទៅនៅចុងខែមីនា បន្តដល់ខែ មេសា និងឧសភា ឆ្នាំ២០១៣ នៅទីក្រុងញូយ៉ក ។ ជួបជាមួយអគ្គនាយកខ្មែរ វ័យ៣៧ឆ្នាំនៃ Season of Cambodia គឺលោក ព្រីម ភឿន (Prim Ploeun) លោកបានថ្លែងថា គម្រោងក្នុងការបង្កើតឱ្យមាន Season of Cambodia នេះឡើង ត្រូវបានចំណាយពេលជិតបីឆ្នាំទម្រាំមានថ្ងៃនេះ ។ វាជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ និងជាលើកទី១ ដែលពុំទាន់មានអ្នកណាអាចសម្រេចបានដូចខ្មែរនៅឡើយ ព្រោះព្រឹទ្ធាចារ្យ គង់ ណៃ ផ្នែកចាប៉ី ដងវែងសាស្ត្រាចារ្យចាស់ទុំ និងវ័យក្មេងដែលអញ្ជើញមកពីសកលវិទ្យាល័យភូមិន្ទ និងវិចិត្រ សិល្បៈស្ថាបនិកសិល្បៈខ្មែរអមតៈលោក អាន ធនផន ប្រធានកម្មវិធីនៃអម្រិតតាសិល្បៈលោក គង់ រិទ្ធីសាល បទសម្ភាសន៍ជាមួយអ្នកផលិតកម្មវិធី និងពិធីការិនីល្បីល្បាញរបស់បណ្តាញទូរទស្សន៍ស៊ីធីអិនអ្នកនាង យុគចិន្តា ព្រមទាំងសិល្បករសិល្បការិនីខ្មែរជាច្រើនរូបភាពដែលអញ្ជើញមកសហរដ្ឋអាមេរិកក្នុងទីក្រុងញូយ៉ក ។ សូមអានបន្តនៅលេខបន្ទាប់ ៕

*អត្ថបទ ដោយ : សុខា*


# ពេទ្យធ្មេញសំរាប់គ្រួសារ
Caring Dental For ALL Ages




FREE
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 07/27/13

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 07/27/13

COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្ច្រាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ីនស្វ៊ីន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com

# បែកបាក់គ្នាគ្រប់គ្រាន់ហើយ ឈឺចាប់គ្រប់គ្រាន់ហើយត្រូវបានគេកេងប្រវ័ញ្ច គ្រប់គ្រាន់ហើយដល់ពេលដែលសហគមន៍ខ្មែរយើងផ្សះផ្សារ!

**ដោយ គង់ សេងលី**


សេងលី គួង

"ខ្ញុំមិនចូលចិត្តជីវភាពរបស់ខ្ញុំ មិនចូលចិត្តអតីកាលមិនទុកចិត្តអ្នកណាទាំងអស់មិនទុកចិត្តប្រព័ន្ធសង្គមទាំងអស់ ។ ទាំងអស់សុទ្ធតែមិនសុច្ចរិត និងពោរពេញដោយការកេងប្រវ័ញ្ច" នេះជាសំដីខ្មែរអាមេរិកាំងម្នាក់មានអាយុប្រមាណ៤០ប្លាយឆ្នាំដែលបាត់បង់ឪពុកម្តាយបងប្អូនប្រុសស្រីក្នុងសម័យវាលពិឃាត ប៉ុល ពត និងបច្ចុប្បន្នគ្មានការងារធ្វើព្រមទាំងទាំងធានារ៉ាប់រងសុខភាពទៀតផង ។ សំដីនេះពិតជាសង្ខេបនូវសតិអារម្មណ៍រួមរបស់ពលរដ្ឋខ្មែរអាមេរិកាំងមួយចំនួនដែលសល់ជីវិតរស់រានពីរបបប្រល័យពូជសាសន៍ ហើយក៏ជាសតិអារម្មណ៍ដែលស្របនឹងលទ្ធផលការសិក្សានានាអំពីសុខភាពសហគមន៍ខ្មែរអាមេរិកាំង ។

ពលរដ្ឋខ្មែរអាមេរិកាំងដែលសេសសល់ជីវិតពីរបបវាលពិឃាតមានសុខភាពលំបាកលំបិនខ្លាំងបើប្រៀបធៀប និងពលរដ្ឋអាមេរិកាំងទូទៅ ។ តាមការសិក្សាមួយដែលសមាគមសុខភាពខ្មែរបានធ្វើឡើងលើពលរដ្ឋខ្មែរអាមេរិកាំងដែលមានអាយុ៣៥ឆ្នាំឡើងទៅនៅក្នុងប៉ែកខាងលិចនៃរដ្ឋម៉ាស្សាឈូសែត និងនៅរដ្ឋកានិកតិកិតចំនួន១៤០នាក់ ក្នុងឆ្នាំ២០១១ អ្នកចូលរួមប្រមាណ៦៧%បានត្រូវប្រាប់ដោយគ្រូពេទ្យរបស់គាត់ថា មានជំងឺវិទ្ធត់ចិត្ត(ប្រៀបនឹង៤%ចំពោះអាមេរិកាំងទូទៅ) .៤០.៧% បានត្រូវប្រាប់ដោយគ្រូពេទ្យរបស់ខ្លួនថា មានរោគលើសឈាម (ចំណែកអាមេរិកាំងទូទៅមានតែ២៩%)២៧%មានរោគទឹកនោមផ្អែម (ប្រៀបនឹង៩% ចំពោះអាមេរិកាំងទូទៅ) ។ ការសិក្សាថ្មីៗរបស់ក្រសួងការពារប្រទេសសហរដ្ឋអាមេរិកទៅលើ អតីតយុទ្ធជនអាមេរិកាំងដែលត្រឡប់មកពីសមរភូមិវិញបានរកឃើញថា ជំងឺផ្លូវចិត្ត និងជំងឺផ្លូវកាយមានទំនាក់ទំនងគ្នា ។ ឧទាហរណ៍អ្នកមានជំងឺផ្លូវចិត្តភាគច្រើនមានជំងឺទឹកនោមផ្អែមដែរ ។

ក្រៅពីមានសុខភាពលំបាកលំបិនការបាត់បង់ទំនុកចិត្តរបស់ពលរដ្ឋខ្មែរទៅលើប្រព័ន្ធសង្គមកិច្ចមានសភាពរាលដាលដែលបង្កផលវិបាកមួយកំរិតទៀតដល់សុខភាពរបស់សហគមន៍ ។ ជាក់ស្តែងលោកតាលោកយាយមួយចំនួនមិនសូវមានជំនឿទៅលើប្រព័ន្ធសុខាភិបាលឡើយ ។ មានពាក្យចចាមអារាមមួយបានលេចឮឡើងថា មន្ទីរពេទ្យ និងគ្រូពេទ្យមួយចំនួនមានបំណងសម្លាប់ដោយចេតនា ព្រោះយល់ថា គាត់ជាបន្ទុកធ្ងន់ដល់សង្គមអាមេរិកាំង ។ លោកតាលោកយាយខ្លះដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យបដិសេធមិនពិសាថ្នាំដែលគ្រូពេទ្យចេញឱ្យដោយសារតែមូលហេតុពាក្យចចាមអារាមនេះ ។ ពលរដ្ឋខ្មែរមួយចំនួនទៀតអស់ទំនុកចិត្តនឹងស្ថាប័ននយោបាយ និងអ្នកនយោបាយ ព្រោះគាត់យល់ថាពួកគេគិតតែខ្លួនឯងផ្តោតការយកចិត្តទុកដាក់លើតែខ្លួនឯង និងជានិច្ចកាលការពារតែផលប្រយោជន៍ខ្លួន និងអំណាចរបស់ខ្លួន ។ ពលរដ្ឋខ្លះទៀតមិនទាំងទុកចិត្តគ្នាឯងដោយខ្លាចគេធ្វើឱ្យខូចប្រយោជន៍ខ្លួនឯង ។ នេះជាមរតកនៃរបបវាលពិឃាតដែលកាលនោះបានបង្ខំឱ្យពលរដ្ឋទូទាំងសមាជិកសមាជិកាក្នុងគ្រួសារសើបយកការណ៍ពីគ្នាទៅវិញទៅមកដើម្បីជីវិតរស់នៅ ។ ជាផលវិបាកសហគមន៍យើងបែកបាក់គ្នារងគ្រោះ និងរកការកេងប្រវ័ញ្ចគ្រប់ជំពូក ។ អ្នកនយោបាយ តទៅទំព័រទី ១៨

# Divided enough, exploited enough, hurt enough, our Community needs to heal!

**By Sengly Kong**

"I hate my life; I hate my past; I do not trust anyone or any systems; they are crooked and exploiting…" said a Cambodian American person of mid 40s who lost parents, brothers and sisters to the Killing Field some 40 years ago and currently unemployed without health insurance. The quote sums up the feeling of many Cambodian holocaust (Killing Field) survivors and is consistent with many scientific studies and literatures on the Cambodian American community.

The Cambodian holocaust survivors are in much poorer health than general population. According to a snowball survey of 140 Cambodian holocaust survivors 35 and older in Connecticut and Western Massachusetts conducted by Khmer Health Advocates and funded by the Center for Disease Control and Prevention (2011) majority of the respondents were told by their doctors that they have had depression (65% vs. 6.7% general population) and PTSD (67% vs. 4% general population). Physical health is not far behind either. The survey found that 40.7% of the respondents were told of having high blood pressure (vs. 29% general population); 27% diabetes (vs.9%); and 8% stroke (vs. 3%). The findings are consistent with studies conducted by Rand Corporation of the survivors in Long Beach, California and many other academic literatures. And re cent studies of the US war veterans conducted by the US Department of Defense found that mental health and physical health are closely linked. That is, those who have PTSD tend to also have diabetes.

Besides the poor health status, lack of trust in systems as reflected in the quote earlier is consequentially pervasive in the survivor community. For example, many elders do not trust health care systems. There is a rumor among the Cambodian elders that hospitals and doctors try to euthanize or kill them off because they are, in their view, a burden to an American society. Some elders who were admitted to hospital even refused to take prescribed medication because they fear that the medicine would kill them. People do not trust political systems and politicians who, in their view, are self-centered, self-impressed, and always look for their own interests, staying in power and enjoying political connection. People do not trust their peers for fear of harming their own interests; this is rooted in a legacy of the infamous Killing Filed regime that was forcing people even family members to spy on one another for survival. Consequently, lack of trust is so pervasive that the community is divided, hurt, and exploited; some few vulture politicians and officials avoid investing in our community citing the community division as their scapegoat.

*Enough is enough!* We need to heal our community. While essentially important to heal our mental and physical health it is equally important to heal the division in our community that is a culprit that has contributed to perpetuating and exacerbating both psychological and physical wounds. We can start healing the community division using principles that our great ancestors adapted and adopted, the principles that our ancestors so cherished in governing the united and prosperous Khmer Empire in the early centuries; these principles are vividly enshrined in the four gigantic smiling faces of the 13th century Bayon temple in Siem Reap, Kingdom of Cambodia.

The great Khmer King Jaya Varaman VII, who ruled the Khmer Empire and was a faithful practitioner of the principles, once said, "the pain and suffering of my people hurt me more than my own pain and suffering." These principles are the 4 Brahmavihara or the four immeasurables, *Metta,* Karuna, Mudita, and Upekkha.

According to the English Wikipedia retrieved on March 30, 2013 from http://en.m.wikipedia.org/wiki/Brahmavihara#section_4, the four immeasurables are defined as follow:

***Metta*** (Pali: metta, Sanskrit: maitri) means Loving-Kindness towards all: the hope that a person will be well; "the wish that all sentient beings, without any exception, be happy."

***Karuna*** (Pali and Sanskrit: karu.a) means Compassion: the hope that a person's sufferings will diminish; "the wish for all sentient beings to be free from suffering."

***Mudita*** (Pali and Sanskrit: mudita) means Empathetic joy (Pali and Sanskrit: mudita): joy in the accomplishments of a person—oneself or another; sympathetic joy; "the wholesome attitude of rejoicing in the happiness and virtues of all sentient beings."

***Upekkha*** (Pali: upekkha, Sanskrit: upek.a) means Equanimity: learning to accept loss and gain, praise and blame, and success and failure, all with detachment, equally, for oneself and for others. Equanimity is "not to distinguish between friend, enemy or stranger, but regard every sentient being as equal. It is a clear-minded tranquil state of mind—not being overpowered by delusions, mental dullness or agitation.

To contribute to a community healing effort, the Cambodia Town Committee is planning to build a replica of the four smiling faces of Bayon in the heart of Lowell Cambodia Town; each smiling face represents each of the four immeasurables or the four Brahmavihara. The replica serves to remind our community to try our best hold ourselves up to these immeasurables for the sake of our community's interests and ourselves. While looking for external resources to realize this project, the committee would passionately appeal to and welcome any contribution in both financial and spirits from members of the community near and far for this noble community-healing project.

GENERAL DENTISTRY
ហួ ឌួង ពេទ្យធ្មេញសម្រាប់គ្រួសារ
466 Merrimack Street. Lowell, MA 01854
( Near City Hall ) / 978-441-1005

យើងទទួលយកគ្រប់ក្រុមហ៊ុនធានារ៉ាប់រង
សុខភាព និងការធានារ៉ាប់រងសុខភាពមនុស្សចាស់
យើងបើកទ្វារទទួលភ្ញៀវ ៥ថ្ងៃ ក្នុងមួយសប្តាហ៍
បិទទ្វារ : ថ្ងៃព្រហស្បតិ៍ និងថ្ងៃ អាទិត្យ
ទូរស័ព្ទដើម្បីណាត់ជួប (978) 441-1005
ម៉ោងធ្វើការពីម៉ោង 10ព្រឹក ដល់ 6ល្ងាច
ថ្ងៃសៅរ៍ ពីម៉ោង 10ព្រឹក ដល់ 4រសៀល
យើងមានបុគ្គលិកនិយាយភាសាខ្មែរ



HOA DUONG, D.M.D., P.C.
GENERAL DENTISTRY
គ្រូពេទ្យជំនាញនិងមានបទពិសោធន៍
ច្រើនឆ្នាំក្នុងការពិនិត្យ
ថែរក្សា និងព្យាបាលជម្ងឺធ្មេញទូទៅ
978-441-1005



Open: Monday, Tuesday, Wednesday, and Friday from 10 a.m. – 6 p.m.
Saturday: from 10 a.m. – 4 p.m.
Closed: Thursday & Sunday
We accept all dental insurance & Medicaid

តមកពីទំព័រទី ៦

## វិស័យសំណង់នៅក្នុងប្រទេសកម្ពុជា...

១០ដុល្លារក្នុងមួយថ្ងៃ រីឯនៅក្នុងប្រទេសកម្ពុជាវិញ កម្មករសំណង់អាចទទួលបានប្រាក់ឈ្នួលជាមធ្យមត្រឹមតែ៥ដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ ។

លោក ធារី លូស្តាវខាវ (Therry lou stau khao) នាយកគ្រប់គ្រងក្រុមហ៊ុន អិល ប៊ីអិល អន្តរជាតិ (LBL International) ជាក្រុមហ៊ុនធំមួយដែលជួលកម្មករជាង៥០០នាក់សម្រាប់គម្រោងសាងសង់ផ្សេងៗរបស់ខ្លួនក្នុងរាជធានីភ្នំពេញ និងនៅក្នុងខេត្តសៀមរាប បានមានប្រសាសន៍ថា មានវិធីមួយដែលអាចទាក់ទាញកម្មករឱ្យវិលចូលមកវិស័យសំណង់បាន គឺត្រូវដំឡើងប្រាក់ឈ្នួលដល់កម្មករ និងផ្តល់ការលើកទឹកចិត្តផ្សេងៗដូចជាផ្តល់កន្លែងស្នាក់នៅក្នុងការដ្ឋានជាដើម ។

លោកមានប្រសាសន៍ថា "យើងត្រូវតែដំឡើងប្រាក់ឈ្នួលដល់ពួកគេ និងផ្តល់កន្លែងស្នាក់នៅដល់ពួកគេដែលពីមុនមកយើងមិនធ្លាប់បានធ្វើ" ។ លោកបានបន្ថែមថា ក្រុមហ៊ុនអិលប៊ីអិលអន្តរជាតិក៏អាចនឹងបង្កើនកម្លាំងពលកម្មរបស់ខ្លួនចំនួន២០%ទៀតដែរ ដើម្បីបំពេញតាមតម្រូវការ ។

លោក ភីតធើ ប្រ៊ីមបល (Peter Brimble) សេដ្ឋវិទូរបស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា វិស័យសំណង់កំពុងតែដើរតួនាទីកាន់តែធំឡើងៗជាលំដាប់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដែលត្រូវបានរំពឹងថា នឹងកើនឡើងយ៉ាងហោចណាស់៧,២% នៅឆ្នាំនេះ ។ វិស័យសំណង់ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នមានចំនួន៦ភាគរយនៃផលិតផលក្នុងស្រុកសរុប ហើយអង្គការមូលនិធិរូបិយវត្ថុអន្តរ-ជាតិបានលើកឡើងកាលពីខែមករាថា វិស័យសំណង់នៅប្រទេសកម្ពុជា "កំពុងរីកចម្រើនដោយសារតែវិស័យអចលនទ្រព្យរីបឡើងវិញ និងដោយសារកំណើនយ៉ាងឆាប់រហ័សផ្នែកឥណទាន" ។

លោក ប្រ៊ីមបល បានមានប្រសាសន៍ថា នៅទីបំផុត ដោយសារបញ្ហាខ្វះកម្លាំងពលកម្មនា-ពេលច្ចុប្បន្ននឹងបង្ខំឱ្យក្រុមហ៊ុនសំណង់នានាដំឡើងប្រាក់ឈ្នួលដល់កម្មករ ។ លោកបានមានប្រសាសន៍ថា "ប្រាក់ឈ្នួលនឹងកើនឡើង ។ ប្រសិនបើមានអ្នកចង់សាងសង់រោងចក្រអគារ និងការអភិវឌ្ឍន៍ថែមទៀត ពេលនោះចំនួនប្រាក់ឈ្នួលនឹងកើនឡើង" ។

លោក ចុង ពិទូ វិស្វករប្រចាំក្រុមហ៊ុនសំណង់វិស្បាន ដែលទទួលបន្ទុកគម្រោងសាងសង់ខុនដូប្រណីតនៅក្នុងខណ្ឌដូនពេញមានប្រសាសន៍ថា ប្រាក់ឈ្នួលអប្បបរមានៅទីនោះបច្ចុប្បន្នប្រហែល១៨.០០០រៀល ក្នុងមួយថ្ងៃ ឬប្រហែល៤,៥ដុល្លារ គឺបានកើនឡើងមួយឆ្នាំមកហើយ ដែលនៅមុននោះ ប្រាក់ឈ្នួលបានត្រឹមប្រហែល១២.០០០រៀលក្នុងមួយថ្ងៃ ។

លោក ចុង ពិទូ បានបន្តថា : "រដ្ឋាភិបាលគួរតែបញ្ចុះតម្លៃម្ហូបអាហារ និងតម្លៃទំនិញ និងតម្លៃសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ ធ្វើដូច្នេះទើបប្រាក់ឈ្នួលរបស់កម្មករអាចគ្រប់គ្រាន់សម្រាប់ការរស់នៅហើយពួកគេនឹងមិនចេញទៅប្រទេសផ្សេងទៀតទេ" ។

យោងតាមលោក ចូល ប្រេស្តុន (Jeol Preston) អ្នកពិគ្រោះយោបល់ប្រចាំមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ដែលតែងតែជួយសង្គ្រោះកម្មករចំណាកស្រុកដែលត្រូវបញ្ជូនពីប្រទេសថៃបានឱ្យដឹងថា មានជនជាតិខ្មែរយ៉ាងតិច៥០០.០០០នាក់ កំពុងធ្វើការនៅក្នុងប្រទេសថៃ នាពេលបច្ចុប្បន្ននេះ ។

លោក ប្រេស្តុន បានបញ្ជាក់ថា តាមការប៉ាន់ប្រមាណមានកម្មករចំណាកស្រុកស្របច្បាប់ ។ ទោះបីជាយ៉ាងនេះក្តីដោយសារប្រទេសថៃផ្តល់ប្រាក់ឈ្នួលខ្ពស់នាំឱ្យមានការទាក់ទាញផងដែរ ។

លោក ប្រេស្តុន បានមានប្រសាសន៍ថា "ពិតណាស់ ការទទួលខុសត្រូវ គឺជាបន្ទុករបស់រដ្ឋាភិបាលជាពិសេសដោយសារការបោះឆ្នោតជិតមកដល់ផង ពេលនេះក្លាយជាប្រធានបទពិភាក្សាជាសា-ធារណៈ ហើយប្រសិនបើគេចង់បញ្ឈប់ការធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើច្រើនពេកតាមរយៈការធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើដោយខុសច្បាប់ និងការជួញដូរមនុស្សគេចាំបាច់ត្រូវដំឡើងប្រាក់ឈ្នួល" នៅក្នុងប្រទេស ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវជាសាធារណៈច្រើនលើកច្រើនសារមកហើយ កុំឱ្យប្រជាពលរដ្ឋខ្មែរប្រថុយធ្វើចំណាកស្រុកទៅក្រៅប្រទេស ដើម្បីស្វែងរកការងារធ្វើ ដោយលោកបានលើកឡើងថា វិស័យដែលរីកដុះដាលនៅក្នុងប្រទេសចាំបាច់ត្រូវការកម្មករក្នុងស្រុក ។

លោក ហ៊ុន សែន បានលើកឡើងនៅក្នុងសុន្ទរកថា កាលពីខែធ្នូនៅក្នុងក្រសួងការងារថា ប្រជាជនខ្មែរ មិនគួរប្រថុយជីវិតរបស់ខ្លួនទៅធ្វើការនៅក្នុងប្រទេសថៃទេ ហើយលោកបានជំរុញឱ្យបណ្តាក្រុមហ៊ុននានាដំឡើងប្រាក់ឈ្នួលឱ្យកម្មករ ដើម្បីអាចរក្សាកម្មករឱ្យនៅក្នុងប្រទេស ។

លោក កែន លូ អគ្គលេខាធិការរបស់សមាគមរោងចក្រការដេរកម្ពុជា មានប្រសាសន៍ថា ឧស្សាហកម្មកាត់ដេរដែលជួលកម្មកររាប់សែននាក់ក្នុងប្រទេសកម្ពុជា ក៏កំពុងប្រឈមនឹងបញ្ហាខ្វះកម្មករដែរ ។ លោកបានបន្តថា បើទោះជាបច្ចុប្បន្ននេះមានការជួលកម្មករប្រហែល៧០.០០០នាក់ក៏ដោយ ក៏ឧស្សាហកម្មនេះអាចស្រូកយកកម្មករប្រមាណ៥០.០០០នាក់ទៀតបានយ៉ាងស្រួលដែរ ៕

*ប្រែសម្រួលដោយ តែម សុខុម និង ចេវ ប៊ុនទី*


# ផ្សារអាតាឡង់ទិក

Atlantic Market

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ដាន់ ស៊ីន** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០






**ទីផ្សារថេរភាពទំនិញតម្លៃថោក**

តមកទំព័រទី ១
## ដកស្រង់សេចក្ដីថ្លែងការណ៍ជុំវិញ...

កាលពីថ្ងៃ ច័ន្ទ ទី១៥ ខែមេសា នៅទីក្រុងបូសស្តុន និងការផ្ទុះឆេះរោងចក្រផលិតជីនៅរដ្ឋតិចសាស់ កាលពីថ្ងៃទី១៧ ខែមេសា កន្លងមកនេះ ។ ព្រឹត្តិការណ៍ទាំងពីរនេះបានកើតឡើងត្រូវចំព្រឹត្តិការណ៍ថ្ងៃ ទី១៧ មេសា ឆ្នាំ១៩៧៥ ដែលពួកកុម្មុយនីស្តខ្មែរក្រហមបានទទួលជ័យជំនះលើរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលបានផ្លាស់ប្តូរកម្ពុជាពីកូនប្រទេសដ៏ល្អស្តួតបូតមួយទៅជាគុកឥតជញ្ជាំង ។

...ដោយធ្លាប់មានបទពិសោធន៍នៃសោកនាដកម្មប្រហាក់ប្រហែលគ្នានេះហើយ ដែលអាត្មាភាពគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នាសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយនឹងក្រុមគ្រួសារទាំងអស់នៃជនរងគ្រោះនៅក្នុងគ្រោះថ្នាក់ទាំងពីរខាងលើ ។

ជាមួយគ្នានេះដែរ អាត្មាភាព និងយើងខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងការឆ្លើយតបខ្លះៗ ចំពោះការចោទប្រកាន់ដ៏អគតិបំផុតដោយក្រុមខ្មែរមួយចំនួនតូច និងមានការលាតត្រដាងសារជាថ្មីដោយសារព័ត៌មានក្នុងរយៈពេលថ្មីៗនេះផងដែរ ។ ជាធម្មតាតាមទំនៀមទំលាប់តាំងពីដូនតាមកនៅរដូវចូលឆ្នាំថ្មី គឺជាឱកាសដ៏សប្បាយរីករាយដែលក្រុមគ្រួសារខ្មែរទាំងឡាយតែងមកជួបជុំគ្នា ដើម្បីប្រារព្ធពិធីបុណ្យឆ្នាំថ្មី ឧទ្ទិសផុសលជំរះនូវអកុសល និងបួងសួងសុំសិរីសួស្តី និងសេចក្តីសុខគ្រប់ៗគ្នា ។ ផ្ទុយទៅវិញមានក្រុមជនអគតិមួយចំនួនតូចឆ្លៀតយកឱកាសបុណ្យចូលឆ្នាំថ្មីខ្មែរ ធ្វើជារនាំងនយោបាយ ដើម្បីបញ្ចេញនូវអំពើហឹង្សា គំនុំគុំគួន មហិច្ឆតា ការច្រណែនឈ្នានីស និងអំពើអកុសលផ្សេងៗបានដើរអុចអាកញុះញង់ប្រជាជនក្នុងបំណងបំបែកបំបាក់សាមគ្គីបង្កើតចលាចលជំលោះនិងបង្កឱ្យមានទំនាស់ដល់ដល់សហគមន៍ខ្មែរដែលកំពុងតែលូតលាស់ឡើង គួរជាទីមោទនភាពរបស់ខ្មែរយើងគ្រប់ៗគ្នា ។

អាត្មាយើងខ្ញុំ សូមទទួលស្គាល់នូវការចាប់អារម្មណ៍ និងការយកចិត្តទុកដាក់របស់បងប្អូនខ្មែរទាំងឡាយ ។ ក្នុងនាមអាត្មាភាពគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នាជាអ្នកគោរពប្រតិបត្តិនូវព្រះពុទ្ធសាសនា, អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នា សូមឱ្យតម្លៃខ្ពស់ដល់សេចក្តីស្មោះត្រង់ និងគោរពត្រឹមត្រូវ , ព្រោះថា ភាពស្មោះត្រង់ និងសច្ចធម៌នេះហើយ ដែលជាមូលដ្ឋានគ្រឹះដ៏មាំដែលអាត្មាភាពនិងយើងខ្ញុំទាំងអស់គ្នាកំពុងខិតខំស្ថាបនាឱ្យមានឡើង ។ អាត្មាភាពនិងយើងខ្ញុំទាំងអស់គ្នាយល់ថាយើងមិនអាចស្ថាបនានូវអ្វីដោយឯកឯងបានឡើយបើគ្មានជំនឿ និងការឧបត្ថម្ភគាំទ្រពីប្រជាជនខ្មែរយើង និងពីពុទ្ធបរិស័ទ **តទៅទំព័រទី ១៥**

20 ANNIVERSARY
ខួបឆ្នាំទី២០
Top Global Leader

* Top Global Leader looking for a few motivated and individuals to mentor
* Work from home
* Independence Business Owner
* Get paid on electricity and credit card processing

*ស្វែងរកអ្នកចូលចិត្ត និងជាបុគ្គលណែនាំគេ (ធ្វើការពេញពេល ឬពេលតិច)
*ធ្វើការនៅផ្ទះ
*ម្ចាស់ពាណិជ្ជកម្មឯករាជ្យ
*ទទួលកំរៃលើការប្រើភ្លើងអគ្គិសនី និងដំណើរការណ៍ប្រើ"ក្រេឌីតខក"

សូមទាក់ទង: SHELLY VU
Cell: (781) 760 - 6526

APSARA WIRELESS COMPUTER
ទើបបើកថ្មី !
GRAND OPENING
285 Chelmsford St. Lowell, Ma 01851
Phone: (978)-455-0075
និយាយភាសាខ្មែរ: (978)-876-2875



▶ មានលក់ Sale
▶ ផ្តល់សេវា Service
▶ ជួសជុល Repair

ទូរស័ព្ទ WIRELESS •កុំព្យូទ័រ •ឡាបថប •បរិក្ខាទូរស័ព្ទ •បង់ថ្លៃប៊ីល (Bill Pays)

សូមទៅមើលកន្លែងផ្សេងទៀត Location II: Happy Computer Service
122 Merrimack Street. Lowell, MA 01852 / ទូរស័ព្ទ: (978) 970-1769

តមកពីទំព័រទី ១៤

# ដកស្រង់សេចក្តីថ្លែងការណ៍ជុំវិញ...

ដ៏ទៃៗទៀតនោះ ។ អាស្រ័យហេតុនេះអាត្មាភាពគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នាបានប្តេជ្ញាចិត្តរក្សានូវការជឿទុកចិត្ត និងសេចក្តីសង្ឃឹមរបស់បងប្អូន និងពុទ្ធបរិស័ទទាំងអស់គ្នាឱ្យបានសក្តិសិទ្ធិ និងខ្ពង់ខ្ពស់បំផុត ។

ទី១-អាត្មាភាពយើងខ្ញុំ សូមឆ្លើយតបទៅនឹងការចោទប្រកាន់មូលបង្កាច់ ពីការចាត់ចែងថវិកាមិនត្រឹមត្រូវនៅក្នុងសហគមន៍ព្រះសង្ឃខ្មែរយើង ។ គួរឱ្យសោកស្តាយណាស់ ការនិយាយបង្ខូចនេះត្រូវបានបង្កើតឡើងដោយបុគ្គលខ្លះដល់អ្នកស្មគ្រចិត្តសហគមន៍ព្រះសង្ឃខ្មែរយើង ។ អាត្មាភាពយើងខ្ញុំទាំងអស់គ្នាមានអារម្មណ៍ថា ការមូលបង្កាច់នេះគ្មានហេតុផល និងខុសស្រឡះពីការពិតជាក់ស្តែង។

ឧទាហរណ៍.សហគមន៍ព្រះសង្ឃខ្មែរ បានផ្ញើសំបុត្រថ្លែងអំណរគុណដល់សប្បុរសជនទាំងឡាយ និងពុទ្ធបរិស័ទជាសមាជិកជិតឆ្ងាយទាំងអស់ដែលបានវិភាគទានដល់វត្ត ។ លិខិតទាំងនេះអាចប្រើប្រាស់បានជាផ្លូវការ និងជាបង្កាន់ដៃសំរាប់គោលបំណងពន្ធដារផង ព្រោះថា សហគមន៍ព្រះ-សង្ឃខ្មែរយើងជាអង្គការមនុស្សធម៌ផ្នែកសាសនាដែលមានលេខនិពន្ធត្រឹមត្រូវចេញដោយក្រសួង IRS នៃសហរដ្ឋអាមេរិក ។

បច្ចុប្បន្ននេះ មានតែព្រះសង្ឃប៉ុណ្ណោះទេ ដែលមានសិទ្ធិដាក់ឈ្មោះនៅគណនីធនាគារ.ប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិ. កិច្ចសន្យាខ្ចីទ្រព្យសម្បត្តិ. កិច្ចសន្យាខ្ចីថវិកា និងនៅលើឯកសារផ្លូវការផ្សេងៗរបស់សហគមន៍ព្រះសង្ឃខ្មែរ ។ ថែមពីលើនេះផងដែរ ច្បាប់លក្ខន្តិកៈរបស់សហគមន៍ព្រះសង្ឃខ្មែរ មិនបានកំណត់ឱ្យមានការស៊ើរើបញ្ជី ឬក៏មិនតម្រូវឱ្យការជម្រះបញ្ជីពីគ្រហស្ថដែលគ្មានសមត្ថកិច្ចណាមួយឡើយ ។ ផ្ទុយទៅវិញ គឺមានតែព្រះសង្ឃប៉ុណ្ណោះ ដែលអាចមានតួនាទីគ្រប់គ្រង និងចាត់ចែងគ្រប់លក្ខណៈទាំងអស់នៃផ្នែកត្រួតពិនិត្យមើលបញ្ជីថវិកា ។ មិនមានចំណុចណាមួយនៃលក្ខន្តិកៈ (សង្ឃធម្មនុញ្ញ) អនុញ្ញាតិឱ្យគ្រហស្ថ ឬអ្នកណាម្នាក់ក្រៅពីព្រះសង្ឃមានសិទ្ធិត្រួតត្រាឡើយ ព្រោះថា សហគមន៍ព្រះសង្ឃខ្មែរមិនមែនជាអង្គការមនុស្សធម៌ ឬជាសហគមន៍ខ្មែរធម្មតានោះឡើយ ។

សហគមន៍ព្រះសង្ឃខ្មែរ មាននីតិក្រម និងគោលការណ៍ផ្នែករៀបចំថវិការត្រឹមត្រូវរួចស្រេចហើយ និងមានបញ្ជីកំណត់ត្រាត្រឹមត្រូវថែមពីលើនេះទៀត សហគមន៍ព្រះសង្ឃខ្មែរយើង ក៏មានបញ្ជីកត់ត្រាទុកត្រឹមត្រូវថែមពីលើនេះទៅទៀត សហគមន៍ព្រះសង្ឃខ្មែរយើងក៏មានបញ្ជីកត់ត្រាទុកត្រឹមត្រូវនូវការចំណាយគ្រប់ប្រភេទដែលយើងបានបង់ថ្លៃដល់អ្នក ដែលបានផ្តល់សេវាកម្មទាំងឡាយរបស់យើងដូចជាក្រុមហ៊ុនផ្តល់សេវាកម្មសាធារណៈ. អ្នកឯកទេសផ្តល់ជំនាញការផ្សេងៗ.មេធាវី. ក្រុមហ៊ុន.សំណង់. អ្នកគូរប្លង់.ព្រះពុទ្ធរូប និងសម្ភារៈប្រើប្រាស់ផ្សេងៗជាដើម ។ល។

អាត្មាភាពគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំថា សកម្មភាពផ្នែកសាសនារបស់យើងបាននឹងកំពុងអនុវត្តទៅប្រកបដោយលក្ខណៈសមរម្យ និងត្រឹមត្រូវទៅតាមច្បាប់រដ្ឋ និងមានតម្លៃខ្ពស់បំផុតតាមព្រះធម៌នៃព្រះពុទ្ធសាសនា ។

អាត្មាភាព និងយើងខ្ញុំស្នើសុំដល់បងប្អូនពុទ្ធបរិស័ទទាំងអស់ សូមមេត្តាមានការអត់ធ្មត់ក្នុងខណៈដែលយើងកំពុងរិះរកវិធានការណ៍ផ្សេងៗដើម្បីផ្តល់នូវព័ត៌មានផ្នែកថវិកា ការរៀបចំចាត់ចែងនូវវិភាគទានរបស់លោកអ្នក ទាំងអស់និងការចំណាយទាំងឡាយ ឱ្យបានត្រឹមត្រូវបំផុតនៅក្នុងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ព្រះសង្ឃខ្មែរយើង ។

ទី២- អាត្មាភាព និងយើងខ្ញុំសូមឆ្លើយតបទៅនឹងការចោទបង្ខូចកិត្តិយស ពីភាពអាសអាភាសចំពោះសមាជិកកំពូលនៃសហគមន៍ព្រះសង្ឃខ្មែរថ្មីៗនេះ ។ ក្នុងព្រះពុទ្ធសាសនាថេរវាទ ព្រះសង្ឃគ្រប់អង្គត្រូវបានព្រះបរមគ្រូហាមឃាត់ដ៏តឹងរឹងបំផុត ក្នុងការធ្វើទំនាក់ទំនងផ្នែកផ្លូវភេទណាមួយ ទោះបីជាមួយបុរស ឬស្ត្រី ។ អាស្រ័យហេតុនេះ ប្រសិនបើការចោទប្រកាន់នេះជាការពិតមែន អាត្មាភាពគ្រប់អង្គ និងយើងខ្ញុំទាំងអស់គ្នា មិនទុកឱ្យមានសកម្មភាពបែបនេះចំពោះសង្ឃអង្គណា ឬបុគ្គលណាម្នាក់ឡើយ ព្រោះថា អំពើទាំងឡាយរបស់ពួកគេមិនបានបញ្ជាក់ពីតម្លៃ ឬក៏ជំនឿរបស់ព្រះពុទ្ធសាសនាខ្មែរយើងឡើយ ។ ចាប់តាំងពីអាត្មាភាព និងយើងខ្ញុំបានដឹងឮពីបញ្ហានេះមកអាត្មាភាព និងយើងខ្ញុំបានខិតខំព្យាយាមស៊ើបអង្កេតរឿងរ៉ាវនេះ ។ អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នា បានខិតខំស្តាប់គ្រប់សេចក្តីការណ៍ និងពាក្យចចាមអារ៉ាមនានា ហើយបានអញ្ជើញអ្នកដែលបានដឹងឮពីព័ត៌មានទាំងឡាយនោះមកធ្វើការបំភ្លឺដល់អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នាផងដែរ ។ ថែមពីលើនេះទៀត អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នា បានប្រមូលព័ត៌មាន. ឯកសារ.ភស្តុតាងទាំងឡាយ ហើយបានប្រគល់ដល់មេធាវីរបស់យើង គឺលោក ហ្វេម ប៊ូមៀល ។ អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នាកំពុងសហការជាមួយក្រសួងមានសមត្ថកិច្ច ដើម្បីពិនិត្យមើលលើការបំពានល្មើសច្បាប់ណាមួយ ទាំងច្បាប់រដ្ឋាភិបាលក្រុងរដ្ឋ ឬច្បាប់រដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិកផងដែរ ។ (នេះគឺជារឿងបុគ្គលមិនមែនជារឿងរបស់សហគមន៍ព្រះសង្ឃខ្មែរទេ) ។

នៅក្នុងសកម្មភាពរបស់បុគ្គលដែលគេចោទនៅក្នុងកាសែតឌីវីឌីនោះ បានបណ្តាលឱ្យមានការរំខានអារម្មណ៍នៅក្នុងសហគមន៍ខ្មែរយើង ប៉ុន្តែជាការចាំបាច់ណាស់ ដែលយើងទាំងអស់គ្នា ត្រូវដឹង និងចងចាំថា ជនណាម្នាក់ដែលបានលួចផលិត. លួចថតរូបភាព.ថតខ្សែសម្លេង.ធ្វើខ្សែអាត់ ឬបានចែកចាយឌីវីឌី តទៅទំព័រទី ១៨

ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"
Free Estimate
Auto Body and Maintenance
BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting



មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



Agent: Roeut Chak

PK Property, Inc.
ក្រុមហ៊ុនអចលនវត្ថុ លក់ ដូរ គ្រប់ប្រភេទ

ភីខេ ប្រភឺធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**
- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥០០ sqft ពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្លក់បៀរ BEER DELI**
- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត Co. Laundry**
- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ** Beer Distributor
- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក Nail Salon**
- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**
www.pkpropertyinc.com to check more listings and office information.

# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហោង

ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងឃាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំថោះ**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះ១នាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើ អាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំមមី**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់១ចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំរកា**

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

**ឆ្នាំឆ្លូវ**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំរោង**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិត១ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំមមែ**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំច**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំខាល**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំម្សាញ់**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

**ឆ្នាំវក**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានៈចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំកុរ**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕


## ក្រុមហ៊ុនធានារ៉ាប់រងដែលបាន បំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com



## East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement



Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជាៈ ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទប់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេង១ជាច្រើនទៀត**

381 West Broadway South Boston, MA 02127
(617) 464 - 0001

# បុណ្យផ្កាសាមគ្គីសង្គ្រោះជាតិ

យើងខ្ញុំជាប្រជាពលរដ្ឋខ្មែរទាំងអស់រស់នៅក្នុងទីក្រុង ឡូវែល, លីន, នូតុន និង រ៉ូដអាយលែន សូមគោរពអញ្ជើញ បងប្អូនជនរួមជាតិខ្មែរទាំងអស់ ចូលរួមបុណ្យផ្កា រស្មីសាម្គីសង្គ្រោះជាតិ ដើម្បីប្រមូលបច្ច័យជួយដំណើរការលទ្ធិប្រជាធិបតេយ្យពិតប្រាកដ នៅប្រទេសកម្ពុជាយើង។ សូមអញ្ជើញចូលរួមចំណែក ដើម្បីប្រទេសជាតិយើងទាំងអស់គ្នា នឹងសេចក្ដីសុខសាន្តរបស់ប្រជាជនខ្មែរ ដែលចង់បានសេរីភាព នឹង ភាពយុត្តិធម៌ ដើម្បីរស់ក្នុងភាពរុងរឿងថ្លៃថ្នូរ នៅលើប្រទេសរបស់ខ្លួន។

**កម្មវិធីបុណ្យ**

ថ្ងៃ១០ រោជ ខែចែត្រ ចត្វាស័ក ព.ស ២៥៥៧ ត្រូវនឹងថ្ងៃអាទិត្យ ទី៥ ខែឧសភា គ.ស ២០១៣ វេលាម៉ោង ៩:៣០នាទីព្រឹក ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់ ដើម្បីនមស្សការ ព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃ ចំរើនព្រះបរិត្ត រាប់បាត បង្សុកូល។ ម៉ោង ១១:០០ព្រឹក វេភត្តាហារប្រគេនព្រះសង្ឃ ទុកជាកិច្ចបង្ហើយបុណ្យ។ ទីកន្លែងនឹងអស័យដ្ឋាន៖ **ភោជនីយដ្ឋាន សំពៅមាស** នៅលើផងវិថី ៤៥០ Chelmsford, St. Lowell, MA 01851 ទូរស័ព្ទ: 978-453-2073។

**ពត៌មានបន្ថែមសូមទាក់ទង**

| Vann Chamroeun | Kham Synoun | Meas Ponnary | Chay Chorisa | Men Monyrathna |
|---|---|---|---|---|
| 978-677-4309 | 603-689-4204 | 978-409-4806 | 978-394-3093 | 978-401-7271 |

**អ្នកផ្ដើមបុណ្យ**

| | |
|---|---|
| ១ | លោក កែវ សម្បត្តិ និង ភរិយា |
| ២ | លោក អ៊ិច សុជាតិ និង ភរិយា |
| ៣ | លោក មាស យន និង ភរិយា |
| ៤ | លោក ខាំ ស៊ីនួន និង ភរិយា |
| ៥ | លោក ឆាន ទូច និង ភរិយា |
| ៦ | លោក ទូច សម្បត្តិ និង ភរិយា |
| ៧ | លោក ម៉ែន វណ្ណៈ និង ភរិយា |
| ៨ | លោក ហួរ សារ៉ាត់ |
| ៩ | លោក នាង សុវណ្ណដារា |

| | |
|---|---|
| ១០ | លោក រស់ សារិន និង ភរិយា |
| ១១ | លោក ប៉េង ឆេន តាន់ និង ភរិយា |
| ១២ | លោក កែ សំខាន់ និង ភរិយា |
| ១៣ | លោក ង៉ោ ឈៀង និង ភរិយា |
| ១៤ | លោក វណ្ណ ចំរើន និង ភរិយា |
| ១៥ | លោក វ៉ែន វត្តនា និង ភរិយា |
| ១៦ | លោកស្រី មាស ប៉ុណ្ណារី និង បុត្រ |
| ១៧ | លោកស្រី ម៉ែន មុន្នីរតនា-ស្វាមី និង បុត្រ |
| ១៨ | លោកស្រី ឆាយ ឆរីសា និង បុត្រ |

## តមកពីទំព័រទី ១៥ ដកស្រង់សេចក្ដីថ្លែងការណ៍ជុំវិញ...

និងសម្ភារៈទាំងនោះ គឺជាការប្រព្រឹត្តខុសច្បាប់នៃសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋនៅក្នុងសហរដ្ឋអាមេរិកនេះ ។ ខណៈដែលក្រសួងមានសមត្ថកិច្ចកំពុងធ្វើការស៊ើបអង្កេតនូវបទល្មើសទាំងឡាយ, អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នាសូមស្នើឱ្យសហគមន៍ខ្មែរយើងមេត្តាអនុវត្តន៍នូវខន្តី,ការអត់ធ្មត់,ការយោគយល់ និងមេត្តាធម៌គ្រប់ៗគ្នា ។ សូមមេត្តាជៀសវាងធ្វើការសន្និដ្ឋាននូវកំហុស ឬធ្វើការផ្ដន្ទាទោសដល់ជនណាម្នាក់ឱ្យសោះ ព្រោះថាមានមនុស្សជាច្រើននាក់ដែលបានបាត់បង់កិត្តិយសមិនមែនគ្រប់គ្រាន់បុគ្គលដែលត្រូវបានគេចោទប្រកាន់តែប៉ុណ្ណោះឡើយ ។ ជាមួយគ្នានេះ សូមមេត្តាធ្វើការកត់សម្គាល់ផងដែរ ចំពោះសកម្មភាពផ្សេងៗដូចខាងក្រោមនេះ :

-វត្តខ្មែរឡូវែល និងសហគមន៍ព្រះសង្ឃខ្មែរបានជួលមេធាវីឱ្យជួយធ្វើការស៊ើបអង្កេតពីប្រភព និងពីយថាភាពនៃខ្សែអាត់ឌីវីឌីអាសអាភាសដែលត្រូវបានចែកចាយពាសពេញសហគមន៍ខ្មែរ និងតាមបណ្ដាសារព័ត៌មានផ្សេងៗ ។

-វត្តខ្មែរឡូវែល និងសហគមន៍ព្រះសង្ឃខ្មែរអនុវត្តច្បាប់នានាប្រចាំសហរដ្ឋអាមេរិក និងព្រះធម៌វិន័យរបស់ព្រះពុទ្ធ ដើម្បីដោះស្រាយបញ្ហាទាំងឡាយនេះ ។

-វត្តខ្មែរឡូវែល និងសហគមន៍ព្រះសង្ឃខ្មែរ សូមអញ្ជើញបងប្អូន និងពុទ្ធបរិស័ទទាំងអស់ដើម្បីមកជួបជាមួយនឹងព្រះសង្ឃាធិបតី សៅ ឃន ឬជាមួយនឹងសមាជិកនៃគណៈកម្មាធិការស្ថាបនា ដើម្បីផ្ដល់ព័ត៌មាន និងជួយក្នុងផ្នែកស៊ើបអង្កេត ក៏ដូចជាជួយដោះស្រាយបញ្ហាផ្សេងៗ ។

-អាត្មាយើងខ្ញុំទាំងអស់គ្នា មានជំនឿថា វត្តខ្មែរឡូវែល និងសហគមន៍ព្រះសង្ឃខ្មែរនឹងអាចមានជ័យជំនះលើឧបសគ្គទាំងឡាយនេះជាក់ជាមិនខានឡើយ ។

បេសកកម្មនៃគម្រោងស្ថាបនាយើង គឺស្ថិតនៅដដែលមិនប្រែប្រួល ឬដួលរលំទៅតាមជំនោរខ្យល់បោកបក់ឡើយ ។

សូមថ្លែងអំណរគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះការសហការណ៍ នឹងការឧបត្ថម្ភគាំទ្រទាំងឡាយ ។

ដោយសេចក្ដីគោរពដ៏ជ្រាលជ្រៅ ក្នុងព្រហ្មវិហារធម៌

-ព្រះសង្ឃាធិបតី **សៅ ឃន ធម្មថេរោ**
ប្រធាន និងព្រះចៅអធិការ

-ព្រះតេជគុណ **ហុក សុវណ្ណ**
អគ្គលេខា និងជំនួយការចៅអធិការ

-ព្រះតេជគុណ **ធី ឈឿប**
ព្រះសង្ឃវត្តខ្មែរឡូវែល

-ព្រះតេជគុណ **ម៉ឹង ធឿន**
ព្រះសង្ឃវត្តខ្មែរឡូវែល

-លោក **ឈឿន សំខាន់**
សមាជិកគណកម្មការស្ថាបនា
វត្តខ្មែរឡូវែល និងមជ្ឈមណ្ឌលវប្បធម៌ ខ្មែរ

-អ្នកស្រី **ម៉ាហ្គារ៉េត ម៉ាទេស**
សមាជិកគណៈកម្មការស្ថាបនា
វត្តខ្មែរឡូវែល និងមជ្ឈមណ្ឌលវប្បធម៌ ខ្មែរ

សម្រួលជូន : មេធាវីលោក ហ្ជេម ប៊ូមៀល
(Attorney James Boumil)

## តមកពីទំព័រទី ១៨ បែកបាក់គ្នាគ្រប់គ្រាន់ហើយ ឈឺចាប់គ្រប់គ្រាន់...

និងមន្ត្រីចរិតសត្វត្មាតខ្លះឆ្លៀតយកចំណេញពីការបែកបាក់របស់សហគមន៍ដោយមិនព្រមធ្វើការវិនិយោគក្នុងសហគមន៍ដោយយកលេសថាសហគមន៍របស់អ្នកយើងមិនស្រុះស្រួលគ្នាជាដើម ។

សហគមន៍យើងពិតជាបែកបាក់ត្រូវគេកេងប្រវ័ញ្ច និងរងគ្រោះគ្រប់គ្រាន់ហើយ ! យើងត្រូវផ្សះផ្សាសហគមន៍របស់យើង ។ ថ្វីត្បិតកាលព្យាបាលសុខភាពផ្លូវចិត្ត និងផ្លូវកាយមានសារៈសំខាន់ដែលចាំបាច់ពលរដ្ឋម្នាក់ៗត្រូវតែផ្ដល់អាទិភាពខ្ពស់ក៏ដោយការផ្សះផ្សារការបែកបាក់នៅក្នុងសហគមន៍ក៏មានសារៈសំខាន់ដែរ ពីព្រោះការបាក់បែក និងបាត់បង់ទំនុកចិត្តរបស់សហគមន៍ក៏ជាដើមចមមួយនៃបញ្ហាជាច្រើនរបស់សហគមន៍យើង ។

យើងអាចចាប់ផ្ដើមផ្សះផ្សារសហគមន៍ដោយប្រើប្រាស់គោលការណ៍ដែលដូនតាយើងបានប្រកាន់យកមកអនុវត្តយ៉ាងខ្ជាប់ខ្ជួន គឺគោលការណ៍ដែលដូនតាគោរព និងអនុវត្តក្នុងការគ្រប់គ្រងចក្រភពខ្មែរកាលពីសតវត្សដើម ។ គោលការណ៍ដ៏ពិសិដ្ឋនេះត្រូវបានឆ្លាក់ដិតលំដោយមុខទាំងបួននៅគ្រប់កំពូលទាំង៥២នៃប្រាសាទបាយ័នទីក្រុងសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា ។

អតីតព្រះវីរៈក្សត្រខ្មែរមួយអង្គព្រះបាទជ័យវរ្ម័នទី៧ ដែលគ្រប់គ្រងចក្រភពខ្មែរ និងជាអង្គក្សត្រដែលប្រកាន់ខ្ជាប់ខ្ជួននូវគោលការណ៍នេះធ្លាប់មានព្រះរាជឱង្ការថា "ការឈឺចាប់ និងទុក្ខវេទនារបស់ប្រជារាស្ត្ររបស់ព្រះអង្គធ្វើឱ្យព្រះអង្គឈឺចាប់ជាងការឈឺចាប់ និងទុក្ខវេទនារបស់ព្រះអង្គផ្ទាល់។" នេះជាព្រះរាជសមានចិត្តដែលឆ្លុះបញ្ចាំងនូវគោលការណ៍ព្រហ្មវិហារធម៌ទាំងបួន គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ។

អនុលោមតាម Wikipedia ជាភាសាអង់គ្លេសដកស្រង់នៅថ្ងៃទី៣០ ខែមិនា ឆ្នាំ ២០១៣ ពីគេហទំព័រនេះ http://en.m.wikipedia.org/wiki/Brahmavihara#section_4 ព្រហ្មវិហារធម៌ទាំងបួនត្រូវបានផ្ដល់និយមន័យ ដូចខាងក្រោម :

**មេត្តា** (បាលី : មេត្តា,សំស្ក្រឹត : មេទ្រី) មានន័យថា ការស្រលាញ់រាប់អានចំពោះមនុស្សទូទៅជាក្ដីសង្ឃឹមថា មនុស្សគ្រប់គ្នាមានសុខុមាលភាពល្អ "ជាក្ដីប្រាថ្នាថា សភាវដែលមានវិញ្ញាណទាំងអស់ ដោយគ្មានការលើកលែងសុទ្ធតែទទួលបានសុភមង្គល។"

**ករុណា** (បាលី និងសំស្ក្រឹត : ករុណា) មានន័យថា ការអាណិតអាសូរ: ជាក្ដីសង្ឃឹមថា ការឈឺចាប់របស់មនុស្សនឹងរលត់បាត់អស់: "ជាក្ដីប្រាថ្នាថា សភាវមានវិញ្ញាណទាំងអស់នឹងចាកផុតពីទុក្ខពីទុក្ខវេទនា"។

**មុទិតា** (បាលី និង សំស្ក្រឹត: មុទិតា) មានន័យថា សមានចិត្តចូលរួមត្រេកអរ : ជាការត្រេកអរចំពោះសមិទ្ធផលរបស់ខ្លួនឯង ឬរបស់អ្នកដទៃ ។ "ជាឥរិយាបថសុច្ចរិតនៃការត្រេកអរចំពោះសុភមង្គល និងគុណសម្បត្តិរបស់សភាវមានវិញ្ញាណទាំងអស់"។



**ឧបេក្ខា** (បាលី : ឧបេក្ខា សំស្ក្រឹត : ឧបេក្សា) មានន័យថា ភាពស្ងប់ក្នុងចិត្ត គឺការរៀនទទួលយកការខាតបង់ និងការចំណេញ, ការសរសើរ និងការស្ដីបន្ទោស និងការជោគជ័យ និងការបរាជ័យ, ដោយការផ្ដាច់ចេញឱ្យអស់នូវកេលេស, ដោយសមធម៌, សំរាប់ខ្លួនឯង និងសំរាប់អ្នកដទៃ ។ ភាពស្ងប់ចិត្តនេះមិនបែងចែករវាងមិត្ត ឬសត្រូវ ឬជនចម្លែកណាទេ ប៉ុន្តែត្រូវចាត់ទុកសភាវមានវិញ្ញាណទាំងអស់ស្មើៗគ្នា ។ ជាអារម្មណ៍ជ្រះថ្លា និងស្ងប់ស្ងាត់មិនរំជួលដោយសារសេចក្ដីភាន់ច្រឡំនានានៃវិញ្ញាណ,ភាពមិនឆ្លាតវៃនៃបញ្ញា ក៏ដូចជាការរញ្ជួយចិត្តជាដើម ។

ដើម្បីចូលរួមចំណែកក្នុងការកសាងសហគមន៍មួយដែលមានឯកភាព និងសាមគ្គីភាពខ្ពស់ គណៈកម្មការក្រុងខ្មែរគ្រោងនឹងកសាងរូបសំណាកព្រហ្មចតុមុខនៅចំកណ្ដាលក្រុងខ្មែរឡូវែល ។ មុខនិមួយៗតំណាងឱ្យព្រហ្មវិហារធម៌ទាំងបួន ។ រូបសំណាកគុណធម៌នេះនឹងរំលឹកដល់សហគមន៍ខ្មែរទាំងមូលឱ្យខិតខំជាអតិមរិមាប្រកាន់យកគោលការណ៍រស់នៅប្រកបដោយព្រហ្មវិហារធម៌ដ៏ពិសិដ្ឋទាំងបួននេះ ដើម្បីឧត្តមប្រយោជន៍របស់សហគមន៍ និងខ្លួនឯង ។

ក្នុងខណៈដែលស្វែងរកការឧបត្ថម្ភពីមជ្ឈដ្ឋានខាងក្រៅដើម្បីសម្រេចផែនការនេះ គណៈកម្មការក្រុងខ្មែរសូមអំពាវនាវ និងស្វាគមន៍នូវការចូលរួមទាំងថវិកា និងស្មារតីពីសំណាក់សហគមន៍ខ្មែរជិតឆ្ងាយទាំងអស់ ដើម្បីសំរេចគំរោងដ៏ថ្លៃថ្លានេះ ៕

# AccuCare

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency

Group Adult Foster Care Program (GAFC)

MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

កម្មវិធី *Group Adult Foster Care (GAFC)* គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហាវាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

### ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

*To be eligibled for GAFC you must:*

- រស់នៅផ្ទះរដ្ឋ *(live in subsidized or public housing)*
- អាយុ ២២ ឆ្នាំឡើងទៅ *(age 22 years and older)*
- មាសហែលស្ដង់ដា *(eligible for Masshealth Standard)*
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ *(need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)*
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក *(have physician statement of your condition)*
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី *(be screened and approved for the program )*

### ផលប្រយោជន៍ទទួលបាន :

Benefits you will get:

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ *(personal care service in your home, up to one hour of service each day)*
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក *(Medication Managemant)*
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ *(an individual care plan developed by a registered nurse and case manager)*
- វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ *(ongoing monitoring of needs)*
- សមាជិកអាចទាក់ទងមក ២៤ម៉ោង *(24-hour access to services)*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:



អ៊ុក តុលាយុទ្ធ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404, Lowell, MA 01852



ពិន ឆាវ៉ាន់ លីន រីវៀរ បូស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200, Allston, MA 02134





"នាងប្រាប់ខ្ញុំគ្រប់យ៉ាង

## ខ្ញុំសប្បាយចិត្តខ្លាំងណាស់។

នាងពេញចិត្តនៅផ្ទះជាមួយយើង។"

CAREGIVER™ HOMES

Caregiver Homes™ ជួយចាស់ជរា និងជនពិការឱ្យរីករាយជាមួយ នឹងគុណភាពខ្ពស់នៃជីវិតនៅផ្ទះ

- បង់ប្រាក់ & បង្រៀបណ្ដុះបណ្ដាល អ្នកថែទាំពេញពេលដែលរស់នៅជាមួយ
- ផ្ដល់ជំនួយ ប្រកបដោយវិជ្ជាជីវៈ ពីគិលានុបដ្ឋាយិកា និង អ្នកថែទាំ ដែលចេះយកចិត្តទុកដាក់
- ជួយអ្នកស្វែងរក & ទទួលបានគ្រប់សេវាដែលចាំបាច់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **866.797.2333** ឬចូលមកគេហទំព័ររបស់យើង។

**WWW.CAREGIVERHOMES.COM**




តមកពីទំព័រទី ១១

# ចូលឆ្នាំខ្មែរនៅ"វត្តសហគមន៍...

នោះបានឱ្យដឹងថា នាង មាយ៉ា ម៉ែន បានដាក់ពាក្យបណ្តឹងទៅតុលាការចំពោះមនុស្ស៥នាក់ដែលមានឈ្មោះ សែម មាស- សុវណ្ណ ឃន- ដានី -ចិក ជូ -លោក លាង- ចោទប្រកាន់ពីបទបរិហាកេរ្តិ៍ផ្សព្វផ្សាយរឿងបុគ្គលមិនពិត។ អង្គប្រជុំបានបង្កើតគណកម្មការមួយភ្លាម១តំណាងឱ្យប្រជាពលរដ្ឋខឹង និងសកម្មភាពមិនប្រក្រតីក្នុងវត្តអារាមដើម្បីជម្រញឱ្យមានការគ្រប់គ្រងវិបត្តសាសនាក្នុងសហគមន៍ខ្មែរ និងដើម្បីជាការគាំទ្រដល់អ្នកទាំង៥ដែលរងការប្តឹងរបស់ ម៉ាយា មែន ។ គណកម្មាការ នោះមានឈ្មោះ សែម មាស - សុវណ្ណ ឃន- សម្បត្ត - រ៉ាឌី ម៉ម- ម៉ែន សុធី- ចន្ថា ខឹម- ប្រិនជិន អៀង- អ្នកស្រីលក្ខិណា... ។ល។ អាច និងមានសមាជិកដល់១៥នាក់ ។

ក្នុងការខឹងសម្បារនោះ មានទៅលើរូបភាពអាក្រាតរូមរ័ករវាងសង្ឃ និងស្ត្រីម្នាក់ ដែលគេជឿចាក់ថា ជាជនឈ្មោះ ញ៉ែម គិមតេង ជាមួយនាង ម៉ាយ៉ា ម៉ែន នៅក្នុងវត្តគឺជាការជាន់ឈ្លីព្រះពុទ្ធសាសនាយ៉ាងចំហរ ព្រះតេជគុណ សៅ ឃន ដែលលាក់បាំងរឿងអាស្រូវនេះ បានត្រូវគេចាត់ទុកថា ក្បត់ការទុកចិត្តដល់ពុទ្ធបរិស័ទដែលធ្លាប់គាំទ្រ ក៏ត្រូវអង្គប្រជុំថ្កោលទោសយ៉ាងចាស់ដៃដែរ ។ ក្នុងលិខិតដ៏វែងមួយរបស់តំណាងវត្ត "សហគមន៍សង្ឃខ្មែរ" មានការឆ្លើយតបដោយបដិសេធគ្រប់ចំណុចទាំងអស់នៃការចោទប្រកាន់ "សូមអានការដកស្រងការផ្សាយលិខិតរបស់តំណាងខាងវត្តភ្ជាប់ជាមួយ" ។

ការចោទប្រកាន់នេះបានរាលដល់បញ្ហាវត្តត្រៃរតនារាម "ថារឿងអាស្រូវបានផ្តើមនៅទីនោះ លោកគ្រូ សៅ ឃន ចេញទៅហើយមែនតែអំណាចរបស់ព្រះអង្គនៅទីនោះដដែល" ម្ល៉ោះហើយរឿងអាស្រូវដែលឆេះនៅវត្តត្រើយម្ខាង និងមកដល់វត្តចាស់វិញដដែលទៀត ។ លោក អ៊ុង រិទ្ធី សមាជិកគណកម្មាការនិន្នាកាវត្តលើបានប្រកាសថា "ខ្ញុំបានខិតខំការពារវត្តត្រៃរតនារាមពីភាពអយុត្តិធម៌អស់ពីកម្លាំងកាយ និងចិត្តនៅតែរឿងមិនចេះចប់ ដូច្នេះខ្ញុំសុំស្នើឱ្យរំលាយគណកម្មាការចាស់ចោលទាំងអស់ ហើយជ្រើសតាំងគណកម្មាការថ្មីដែលមិនកាន់ខាងលើ ឬខាងក្រោមមកគ្រប់គ្រងជំនួស ហើយបញ្ចូលវត្តទាំងពីរឱ្យមកតែមួយវិញ" សម្លេងទះដៃរំពងទទួលយ៉ាងអបអរសាទរយ៉ាងពេញចិត្តពីអង្គប្រជុំ ។ យើងបានសាកសួរភ្លាម១ទៅលោក ដារារិទ្ធ សមាជិកគណកម្មាការវត្តនិន្នាការវត្តក្រោម លោកក៏បានតបភ្លាមមកវិញដែរថា "ខ្ញុំយល់ស្របទាំងស្រុងហើយ តែមិនដឹងថា ត្រូវមានយន្តការណ៍របៀបណា ដើម្បីកុំឱ្យដាច់រយៈការគ្រប់គ្រងពីព្រោះគណកម្មការវត្តមានភារកិច្ចចេញថ្លៃទឹកថ្លៃភ្លើង និងចំណាយផ្សេង១ជាប្រចាំមិនឱ្យដាច់ទេ" ។ នៅលើចំណូលចិត្តរបស់មហាជន និងនៅលើសំណើរ និងចម្លើយដែលដូចជាមានភាពចុះសម្រុងគ្នាជាលើកដំបូងនេះភាពងាយស្រួលក្នុងការបញ្ចូលវត្តទាំងពីរឱ្យត្រឡប់មកតែមួយវិញក៏បានផុសឡើងដែរ ។ តែស្ថានភាពរបៀបនេះបានកើតឡើងម្តងហើយ កាលពីតុលាការចេញបញ្ហាឱ្យបង្កើតគណកម្មាការចម្រុះតែមួយមកគ្រប់គ្រងវត្តទាំងពីរ កាលពី៣-៤ឆ្នាំមុន តែគម្រោងនេះ បានត្រូវបរាជ័យដោយភាពមិនស្មោះត្រង់ និងភាពមិនឯករាជ្យ ៕



**ខ្មែរផុស**